00867425

E251

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 07 / 12 / 2012
ម៉ោង (Time/Heure): 16:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឱត្តារ**

កាលបរិច្ឆេទ: ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ពាក់ព័ន្ធនឹងភាពមិនប្រក្រតី ដែលតាមការចោទប្រកាន់ថាបានកើតឡើងនៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ (ឯកសារលេខ E221, E223, E224, E224/2, E234, E234/2, E241 AND E241/1)

---

**សហព្រះរាជអាជ្ញា**

ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**

នួន ជា
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**

សុន អរុណ
Michiel PESTMAN

Victor KOPPE
អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Arthur VERCKEN
Jacques VERGÈS
Anta GUISSÉ

00867427

## ១. សេចក្តីផ្តើម

១. សេចក្តីសម្រេចនេះគឺជាការសម្រេចរួមលើសំណើសុំទាំងអស់ដែលបានធ្វើឡើងនាពេលថ្មីៗ ដោយក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹងភាពមិនប្រក្រតីដែលបានចោទប្រកាន់ និងកំហុសនីតិវិធីផ្សេងទៀត ទាក់ទិននឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ មុនពេលសវនាការជំនុំជម្រះក្តីលើសំណុំរឿង ០០២/០១[១]។ ផ្នែកមួយនៃសំណើសុំលើកទីមួយរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធនឹង

[១] សំណើរបស់ អៀង សារី សុំស្តាប់ការបង្ហាញភស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីររបស់ ក.ស.ច.ស ដែលកើតមាននូវភាពមិនប្រក្រតី ដែលអាចនឹងចាត់ទុកថាជាការលេងល្បិចភ្នែក ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ E221 ("សំណើសុំលើកទីមួយរបស់ អៀង សារី")។ សំណើរបស់ អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬ ការថតសម្លេងនានា ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ E224 ("សំណើសុំលើកទីពីររបស់ អៀង សារី")។ មតិគាំទ្រសំណើរបស់លោក អៀងសារី E221 និងស្នើសុំដល់អង្គជំនុំជម្រះសាលាដំបូងឱ្យបង្គាប់ដល់សហព្រះរាជអាជ្ញាធ្វើការកែតម្រូវបញ្ជីសក្ខីកម្មជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាមានបំណងដាក់បញ្ចូលក្នុងការពិភាក្សាដេញដោល ជំនួសឱ្យសក្ខីកម្មផ្ទាល់មាត់ ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ E223 ("សំណើសុំលើកទីមួយរបស់ ខៀវ សំផន")។ មតិគាំទ្រសំណើរបស់លោក អៀងសារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសំណើទៅការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្ថិភាពឯកសារសម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E224/2 ("សំណើសុំលើកទីពីររបស់ ខៀវ សំផន")។ សំណើរបស់ អៀង សារី សុំអង្គជំនុំជម្រះសាលាដំបូងឱ្យ ក.ស.ច.ស ធ្វើការបញ្ជាក់ ទាក់ទងនឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងការកោះហៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ឱ្យផ្តល់ភស្តុតាង ទាក់ទងនឹងការស្តាប់ចម្លើយនេះ ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E234 ("សំណើសុំលើកទីបីរបស់ អៀង សារី")។ សំណើរបស់លោក អៀង សារី ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការជាសាធារណៈ និងទទួលយកភស្តុតាងពាក់ព័ន្ធនឹងទម្លាប់អនុវត្តន៍ជាទូទៅ និង លក្ខណៈប្រព័ន្ធនៃការស្តាប់យកចម្លើយ ដោយពុំមានការថតសម្លេង ឬ រូបភាព ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E241 ("សំណើសុំលើកទីបួនរបស់ អៀង សារី")។ សេចក្តីជូនដំណឹងស្តីពីការចូលរួមជាមួយសំណើលេខ E-234 របស់ អៀង សារី ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E234/2 ("សំណើសុំចូលរួមរបស់ នួន ជា") និងញត្តិគាំទ្រ "*សំណើរបស់លោក អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើសវនាការជាសាធារណៈ និងទទួលយកភស្តុតាងពាក់ព័ន្ធនឹងទម្លាប់អនុវត្តជាទូទៅ និងជាលក្ខណៈប្រព័ន្ធនៃការស្តាប់ចម្លើយ ដោយពុំមានការថតសម្លេង ឬ រូបភាព*" ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E241/1 ("សំណើសុំចូលរួមរបស់ ខៀវ សំផន")។

ការជំទាស់ទៅនឹងបញ្ជីស្ដីពីកំណត់ហេតុនៃការស្ដាប់ចម្លើយជាលាយលក្ខណ៍អក្សរ ដែលសហព្រះរាជអាជ្ញាគ្រោងនឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបានដោះស្រាយដោយឡែកពីនេះ[២]។

## ២. **<u>សារធាតុ</u>**

### ២.១. <u>សំណើរបស់ អៀង សារី សុំស្ដាប់ភស្ដុតាងពាក់ព័ន្ធនឹងការស្ដាប់ចម្លើយសាក្សី ភី ភួន ធ្វើឡើងដោយ ក.ស.ច.ស</u>

២. ក្រុមមេធាវីការពារក្ដី អៀង សារី ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅអ្នកបកប្រែដែលមានវត្តមានក្នុងអំឡុងពេល ក.ស.ច.ស ស្ដាប់ចម្លើយសាក្សី ភី ភួន មកធ្វើជាសាក្សី។ ផ្អែកតាមការវាយតម្លៃលើខ្សែអាត់សម្លេងនៃការស្ដាប់ចម្លើយរបស់សាក្សី ភី ភួន ក្នុងពេលសវនាការជំនុំជម្រះ និងភាពពុំស៊ីសង្វាក់គ្នារវាងការស្ដាប់ចម្លើយផ្សេងៗរបស់ ក.ស.ច.ស ជាមួយសាក្សីរូបនេះ ក្រុមមេធាវីការពារក្ដីបានចោទប្រកាន់ថា ការស្ដាប់ចម្លើយរបស់ ក.ស.ច.ស ជាមួយនឹងសាក្សីរូបនេះ ត្រូវបានរៀបចំឡើង ដោយមានការរៀបចំសំណួរ និងចម្លើយទុកជាមុន ដោយផ្អែកលើការស្ដាប់ចម្លើយនាពេលមុនដែលពុំមានការថតសម្លេងទុក ហើយបន្ទាប់មកត្រូវបានរៀបចំឱ្យដូចជាការស្ដាប់ចម្លើយមែនទែន។ ក្រុមមេធាវីការពារក្ដីបានសន្និដ្ឋានថា ការធ្វើដូច្នេះគឺជាការបំពេញកិច្ចស៊ើបសួរមិនត្រឹមត្រូវមួយ ដែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើអន្តរាគមន៍[៣]។

---

[២] *សូមមើល* សំណើសុំលើកទីមួយរបស់ ខៀវ សំផន កថាខណ្ឌ ៦-២២។ *សូមមើលផងដែរ* អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សវនាការដេញដោលលើកឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្ដុតាងគាំទ្រ (ឯកសារ E223)" ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E223/2 និងសេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារលេខ E96/7 ("សេចក្ដីសម្រេចលើការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី") កថាខណ្ឌ ៣៦ (ដែលបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងកំណត់ពេលសវនាការនាពេលវេលាសមស្រប ឬក៏ផ្ដល់ឱកាសឱ្យភាគីដាក់ការជំទាស់ដែលពាក់ព័ន្ធទៅនឹងសំណើរបស់ភាគីស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវឯកសារទាក់ទិននឹងការជម្លៀសប្រជាជន)។

[៣] សំណើសុំលើកទីមួយរបស់ អៀង សារី បុព្វកថា និងកថាខណ្ឌ ១-៨ និង ១៥-២០។

៣. ជាការឆ្លើយតប សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ការចោទប្រកាន់លើភាពមិនប្រក្រតីនៃកិច្ចស៊ើបសួរ ពុំអាចលើកឡើងក្នុងអំឡុងពេលនៃកិច្ចដំណើរការជំនុំជម្រះក្តីនោះទេ ដោយហេតុថា ក្រុមមេធាវីការពារក្តីមានឱកាសយ៉ាងច្រើនក្នុងការដោះស្រាយបញ្ហាទាំងនេះក្នុងដំណាក់កាលមុនសវនាការ និងថា សំណើសុំលើកទីមួយរបស់ក្រុមមេធាវីការពារក្តី អៀង សារី គួរត្រូវបដិសេធចោល[៤]។ ម្យ៉ាងវិញទៀត សក្ខីកម្មក្នុងសវនាការលើសាក្សី ភី ភួន ដែលរួមទាំងការដេញដោលដោយក្រុមមេធាវីការពារក្តីផងនោះ នាពេលកន្លងមក បានការពារគ្រប់គ្រាន់ទៅលើសិទ្ធិទទួលការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទចំពោះគ្រប់បញ្ហានៃកំហុសនីតិវិធីដូចបានចោទប្រកាន់ ហើយយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុង អ.វ.ត.ក ពុំតម្រូវឱ្យអ្នកស៊ើបអង្កេត ក.ស.ច.ស ធ្វើការថតសម្លេងនៃការស្តាប់ចម្លើយសាក្សីនេះឡើយ[៥]។ ចំណុចចុងក្រោយ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា នៅពេលធ្វើការទាក់ទង ដោយផ្ទាល់ជាមួយនឹងអ្នកបកប្រែ ក្រុមមេធាវីការពារក្តី អៀង សារី បានបំពានលើវិធានផ្ទៃក្នុងរួចទៅហើយ ដែលវិធាននេះបានផ្តល់សមត្ថកិច្ចស៊ើបសួរផ្តាច់មុខឱ្យទៅសហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះសាលាដំបូង ហើយបានហាមឃាត់ភាគីមិនឱ្យធ្វើការជ្រៀតជ្រែកសាក្សីឡើយ[៦]។

## ២.២. សំណើរបស់ អៀង សារី សុំការឆ្លើយបំភ្លឺពី ក.ស.ច.ស ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី អឿន តាន

៤. ក្រុមមេធាវីការពារក្តី ក៏បានស្នើអង្គជំនុំជម្រះសាលាដំបូងឱ្យសុំការឆ្លើយបំភ្លឺពី ក.ស.ច.ស ថាតើអ្នកស៊ើបអង្កេតមានខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ដែរ ឬទេ។ ក្នុងអំឡុងពេលស្តាប់ចម្លើយសាក្សីរូបនេះនៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ សាក្សី អឿន តាន ត្រូវបានចោទប្រកាន់ថាបានឆ្លើយបញ្ជាក់ថា រូបគាត់ក៏ត្រូវបានគេស្តាប់ចម្លើយមុនថ្ងៃនោះមួយថ្ងៃផងដែរ។ ទោះបីជាយ៉ាងនេះក្តី ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយនាថ្ងៃនោះ ពុំមាន

---

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើឱ្យបង្គាប់ការបង្ហាញភ័ស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីរ ធ្វើឡើងដោយ ក.ស.ច.ស ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E221/1 ("ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីមួយរបស់ អៀង សារី") កថាខណ្ឌ ២ និងកថាខណ្ឌ ៥-៩។

[៥] ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីមួយរបស់ អៀង សារី" កថាខណ្ឌ ១០-១៦។

[៦] ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីមួយរបស់ អៀង សារី" កថាខណ្ឌ ៤ និងកថាខណ្ឌ ២០-២២។

00867430

ឡើយ[៧]។ ក្រុមមេធាវីការពារក្តី អៀង សារី បានសន្និដ្ឋានបន្ថែមទៀតថា ការស្តាប់ចម្លើយសាក្សីរូបនេះ មានវិការៈ ដោយសារតែការបំពេញកិច្ចរបស់អ្នកស៊ើបអង្កេត[៨]។ ហេតុដូច្នេះ ភាពអាចជឿជាក់បាននៃភស្តុតាងរបស់សាក្សីរូបនេះ ត្រូវរងនូវផលប៉ះពាល់ ហើយដោយពុំមានខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយលើកទីមួយនោះ ក្រុមមេធាវីការពារក្តី អៀង សារី ពុំអាចធ្វើការតវ៉ាឲ្យបានសមស្របលើភស្តុតាងរបស់សាក្សីរូបនេះឡើយ ដែលជាហេតុធ្វើឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ[៩]។ ក្រុមមេធាវីការពារក្តី ខៀវ សំផន គាំទ្រសំណើសុំលើកទីមួយ និងលើកទីពីររបស់ក្រុមមេធាវីការពារក្តី អៀង សារី[១០]។

៥. សហព្រះរាជអាជ្ញាពុំជំទាស់នឹងសំណើសុំលើកទីពីររបស់ក្រុមមេធាវីការពារក្តី អៀង សារី ឡើយ ដោយសំណើសុំនេះស្នើសុំព័ត៌មានបន្ថែមពី ក.ស.ច.ស ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី អឿន តាន នៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨។ ទោះបីជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាបានបដិសេធការលើកឡើងថា ភស្តុតាងនៃសាក្សីរូបនេះ ឬ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អៀង សារី ត្រូវបានប៉ះពាល់[១១]។ ពុំមានភស្តុតាងអ្វីដែលបានបង្ហាញថា សាក្សីរូបនេះត្រូវបានគេជម្រុញឲ្យផ្តល់សក្ខីកម្មក្លែងក្លាយក្នុងពេលស្តាប់ចម្លើយដែលពុំបានថតខ្សែអាត់សម្លេងទុកនោះទេ[១២]។ ទោះក្នុងករណីណាក៏ដោយ ភាពមិនប្រក្រតីនៃនីតិវិធីក្រោមក្របខណ្ឌគតិយុត្ត អ.វ.ត.ក ត្រូវបានចាត់ទុកថាបានដោះស្រាយរួចរាល់អស់ហើយតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ក្រុមមេធាវីការពារក្តីមានឱកាសជាច្រើនក្នុងការតវ៉ាលើភស្តុតាងនៃសាក្សីរូបនេះ ក្នុងអំឡុងពេលសវនាការស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះ និងក្នុងដំណាក់កាលមុនអង្គសេចក្តី។ ចំណុចចុងក្រោយ កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរធ្វើឡើងដោយ ក.ស.ច.ស បានសង្ខេបសក្ខីកម្មរបស់សាក្សី

---

[៧] សំណើសុំលើកទីពីររបស់ អៀង សារី កថាខណ្ឌ ១-៥។

[៨] សំណើសុំលើកទីពីររបស់ អៀង សារី កថាខណ្ឌ ៦-៨។

[៩] សំណើសុំលើកទីពីររបស់ អៀង សារី កថាខណ្ឌ ១៣-១៤។

[១០] *សូមមើល* សំណើសុំលើកទីមួយរបស់ ខៀវ សំផន កថាខណ្ឌ ១-៥ និងសំណើសុំលើកទីពីររបស់ ខៀវ សំផន កថាខណ្ឌ ១-២។

[១១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី ក.ស.ច.ស អំពីអត្ថិភាពនៃកំណត់ត្រា ឬ ការថតសម្លេងនានា ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨" ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១២ ឯកសារលេខ E224/1 ("ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីពីររបស់ អៀង សារី") កថាខណ្ឌ ២ និងកថាខណ្ឌ ២១។

[១២] ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីពីររបស់ អៀង សារី កថាខណ្ឌ ១៦ និងកថាខណ្ឌ ១៨-២០។

រូបនេះបានយ៉ាងត្រឹមត្រូវ ហើយវិធានផ្ទៃក្នុងពុំតម្រូវឱ្យអ្នកស៊ើបអង្កេតថតខ្សែអាត់សម្លេងរាល់ការធ្វើទំនាក់ទំនងជាមួយសាក្សីនោះឡើយ[១៣]។

## ២.៣. អៀង សារី ខៀវ សំផន និង នួន ជា ស្នើសុំការឆ្លើយបំភ្លឺពី ក.ស.ច.ស ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី នង សុផង់

៦. ក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តី ខៀវ សំផន ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងសុំការឆ្លើយបំភ្លឺពី ក.ស.ច.ស ថាតើអ្នកស៊ើបអង្កេតមានខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ដែរ ឬទេ ហើយក៏បានស្នើសុំឱ្យកោះហៅអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ដែលបានស្តាប់ចម្លើយសាក្សីរូបនេះផងដែរ។ ក្រុមមេធាវីការពារក្តី អៀង សារី បានសន្និដ្ឋានថា ខ្លួនមានសិទ្ធិលើកឡើងអំពីកំហុសទាំងឡាយដែលកើតមាននៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរ ហើយអង្គជំនុំជម្រះសាលាដំបូងគួរចាត់គ្រប់វិធានការចាំបាច់ និងសមហេតុផលទាំងអស់ ដើម្បីរកឱ្យឃើញនូវភាពមិនប្រក្រតីទាំងនេះ[១៤]។ ក្រុមមេធាវីការពារក្តីបានចោទប្រកាន់ថា ការស្តាប់ចម្លើយបឋមធ្វើឡើងដោយ ក.ស.ច.ស ជាមួយនឹងសាក្សីរូបនេះ ពុំត្រូវបានថតសម្លេងទុក ហើយក៏ពុំត្រូវបានអ្នកស៊ើបអង្កេត ក.ស.ច.ស សរសេរបញ្ចូលនៅក្នុងកំណត់ហេតុផងដែរ។ ហេតុដូច្នេះ ភាពជឿជាក់បាននៃសក្ខីកម្មរបស់សាក្សីរូបនេះ បានទទួលរងនូវផលប៉ះពាល់។ ដោយសារពុំមានខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយលើកទីមួយនោះ ក្រុមមេធាវីការពារក្តី អៀង សារី ពុំអាចធ្វើការតវ៉ាបានសមស្របលើភស្តុតាងរបស់សាក្សី នង សុផង់ ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទ[១៥]។

៧. ទោះបីជាមានការយល់ស្របថា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ចាប់ពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ គួរត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងក៏ដោយ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ផ្នែកផ្សេងទៀតនៅក្នុងសំណើសុំរបស់ក្រុមមេធាវីការពារក្តី គួរត្រូវបានបដិសេធ

---

[១៣] ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីពីររបស់ អៀង សារី កថាខណ្ឌ ១៦ និងកថាខណ្ឌ ៦-១៧។

[១៤] សំណើសុំលើកទីបីរបស់ អៀង សារី កថាខណ្ឌ ១៣-២៣។

[១៥] សំណើសុំលើកទីបីរបស់ អៀង សារី កថាខណ្ឌ ៧ និងកថាខណ្ឌ ១០។ *សូមមើលផងដែរ* សំណើសុំលើកទីពីររបស់ ខៀវ សំផន កថាខណ្ឌ ៣ និងកថាខណ្ឌ ៦។

00867432

ចោល[១៦]។ សំណើសុំនេះខកខានពុំបានបង្ហាញកំហុសណាមួយ ដែលអាចផ្តល់ជាយុត្តិកម្មឱ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យមានការស៊ើបសួរបន្ថែមឡើយ ហើយយ៉ាងណាក៏ដោយកំហុសនីតិវិធីត្រូវបានសន្មតថាត្រូវបានដោះស្រាយរួចរាល់អស់ហើយតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះ[១៧]។ ក្រុមមេធាវីការពារក្តីមានឱកាសយ៉ាងច្រើនដើម្បីពិនិត្យដេញដោលសាក្សីលើខ្លឹមសារនៃសក្ខីកម្ម និងនីតិវិធីដែលបានអនុវត្តក្នុងអំឡុងពេលនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស ហើយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ពុំមានកាតព្វកិច្ចណាមួយត្រូវថតសម្លេងការស្តាប់ចម្លើយដែលខ្លួនបានធ្វើឡើងជាមួយនឹងសាក្សីឡើយ[១៨]។ ចំណុចចុងក្រោយ សំណើសុំលើកទីបីរបស់ក្រុមមេធាវីការពារក្តី អៀង សារី លើកឡើងដោយពុំសមស្របអំពីការបំពេញកិច្ចពុំត្រឹមត្រូវរបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ហើយពុំគោរពតាមសេចក្តីណែនាំមុនៗរបស់អង្គជំនុំជម្រះសាលាដំបូងឡើយ[១៩]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ក្រុមមេធាវីការពារក្តី ខៀវ សំផន ខកខានពុំបានលើកឡើងអំពីអង្គហេតុ និងអង្គច្បាប់មកធ្វើជាមូលដ្ឋាននៃសំណើសុំរបស់ខ្លួនឡើយ។ ដូច្នេះ សំណើសុំនេះគួរត្រូវបដិសេធចោល ជាពិសេស នៅពេលដែលសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនជាប់ចោទត្រូវបានការពារយ៉ាងត្រឹមត្រូវតាមរយៈការដេញដោលសាក្សី នង សុផង់ ក្នុងពេលធ្វើសវនាការនោះ[២០]។

៨. នៅក្នុងសេចក្តីសន្និដ្ឋានបន្ថែមរបស់ខ្លួនក្នុងការគាំទ្រសំណើសុំលើកទីបីរបស់ក្រុមមេធាវីការពារក្តី អៀង សារី ក្រុមមេធាវីការពារក្តី នួន ជា បានសន្និដ្ឋានថា ប្រសិនបើអង្គជំនុំជម្រះទទួលយកភាពមិនប្រក្រតីនៃកិច្ចស៊ើបសួរបែបនេះ ករណីនេះនឹងជម្រុញឱ្យតុលាការក្នុងស្រុកក្នុងប្រទេសកម្ពុជា

---

[១៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់លោក អៀង សារី សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ស្វែងរកការបំភ្លឺពី ក.ស.ច.ស ទាក់ទិននឹងការស្តាប់ចម្លើយសាក្សី នង សុផង់ នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងកោះហៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ឱ្យផ្តល់ភស្តុតាងទាក់ទងនឹងការធ្វើបទសម្ភាសន៍នេះ" ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ឯកសារលេខ E234/1 ("ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីបីរបស់ អៀង សារី") កថាខណ្ឌ ៤ និងកថាខណ្ឌ ៣៤។

[១៧] ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីបីរបស់ អៀង សារី កថាខណ្ឌ ២ ; ៥ និង ១៦-១៧។

[១៨] ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីបីរបស់ អៀង សារី កថាខណ្ឌ ១៨-២៨។

[១៩] ចម្លើយតបរបស់ ក.ស.ព ទៅនឹងសំណើសុំលើកទីបីរបស់ អៀង សារី កថាខណ្ឌ ២៩-៣២។

[២០] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន គាំទ្រសំណើរបស់លោក អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើសំណើទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្ថិភាពខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨" ឯកសារលេខ E224/3 កថាខណ្ឌ ៣ និងកថាខណ្ឌ ៦-២០។

យកគំរូតាម ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់កេរដំណែលនៃ អ.វ.ត.ក[២១]។ ក្រុមមេធាវីការពារក្តី នួន ជា ក៏បានសន្និដ្ឋានផងដែរថា ក្នុងនាមជាស្ថាប័នទទួលបន្ទុកស្វែងរកការពិត អង្គជំនុំជម្រះគួរមានចំណាប់អារម្មណ៍ខ្លាំងចំពោះភាពមិនប្រក្រតីនៃកិច្ចស៊ើបសួរ[២២] ហើយក្រុមមេធាវីការពារក្តី នួន ជា ក៏បានផ្តល់ឧទាហរណ៍ផងដែរថា ក្របខណ្ឌគតិយុត្តនៃ អ.វ.ត.ក ពុំបានហាមឃាត់ភាគីមិនឱ្យស្វែងយល់អំពីភាពទុកចិត្តបាន និងភាពអាចជឿជាក់បានលើសាក្សី ក្នុងអំឡុងពេលនៃកិច្ចដំណើរការសួរតទល់នោះឡើយ[២៣]។ ក្រុមមេធាវីការពារក្តី នួន ជា ទទួលស្គាល់ថា វិធានផ្ទៃក្នុងពុំតម្រូវឱ្យអ្នកស៊ើបអង្កេតថតខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សីទាំងនោះមែន។ ទោះបីជាយ៉ាងនេះក្តី ក្រុមមេធាវីការពារក្តី នួន ជា បានសន្និដ្ឋានថា ដោយហេតុថាអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានថតខ្សែអាត់សម្លេងស្ទើរតែគ្រប់ការស្តាប់ចម្លើយទាំងអស់ ហេតុដូច្នេះ ការខកខានពុំបានថតខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយមួយចំនួន បង្កើតឱ្យមានភាពសង្ស័យថាតើហេតុអ្វីការស្តាប់ចម្លើយជាក់លាក់មួយចំនួននោះពុំត្រូវបានថតខ្សែអាត់សម្លេង ហើយតើមានការពិភាក្សាគ្នាអ្វីខ្លះក្នុងពេលដែលពុំមានការថតខ្សែអាត់សម្លេងនោះ[២៤]។ ចំណុចចុងក្រោយ ក្រុមមេធាវីការពារក្តី នួន ជា បានសន្និដ្ឋានថា ខ្លួនបានតំណាងផលប្រយោជន៍កូនក្តីខ្លួនដោយយកចិត្តទុកដាក់នៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ ប៉ុន្តែពុំតម្រូវឱ្យស្តាប់គ្រប់ខ្សែអាត់ថតសម្លេងនៃការស្តាប់ចម្លើយទាំងអស់នោះទេ ដោយសារ អ.វ.ត.ក មានកំណត់ហេតុសង្ខេបជាលាយលក្ខណ៍អក្សរជាឯកសារចំបង និងដោយសារតែភាពជាក់ស្តែងដែលពុំអាចធ្វើទៅរួចលើការស្តាប់ខ្សែអាត់សម្លេងដែលមានរយៈពេលរាប់រយម៉ោងឯណោះនោះ[២៥]។

៩. សហព្រះរាជអាជ្ញាបានលើកឡើងថា សំណើសុំចូលរួមរបស់ក្រុមមេធាវីការពារក្តី នួន ជា គឺត្រូវបានធ្វើឡើងហួសពេលកំណត់[26]។ សហព្រះរាជអាជ្ញាក៏បានអះអាងថា ក្រុមមេធាវីការពារក្តី នួន ជា គ្មានផលប្រយោជន៍អ្វីដែលត្រូវនិយាយពីកេរតំណែលតុលាការទេ[២៧]។ ជាពិសេសជាងនេះ ទៀតនោះ

---

[២១] សំណើសុំចូលរួមរបស់ នួន ជា កថាខណ្ឌ ១-៨ និងកថាខណ្ឌ ៣២។

[២២] សំណើសុំចូលរួមរបស់ នួន ជា កថាខណ្ឌ ៩-១០។

[២៣] សំណើសុំចូលរួមរបស់ នួន ជា កថាខណ្ឌ ១១-១២។

[២៤] សំណើសុំចូលរួមរបស់ នួន ជា កថាខណ្ឌ ១៤-១៩។

[២៥] សំណើសុំចូលរួមរបស់ នួន ជា កថាខណ្ឌ ១៣ និងកថាខណ្ឌ ២០-២៦។

[២៦] ចម្លើយរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើសុំចូលរួមរបស់ នួន ជា ទៅនឹងសំណើរបស់ អៀង សារី លេខ E234 ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២។ ឯកសារ E234/1 កថាខណ្ឌ ១។

[២៧] ក.ស.ព ឆ្លើយទៅនឹងសំណើសុំចូលរួមរបស់ នួន ជា ពីកថាខណ្ឌ ២ ដល់ កថាខណ្ឌ ៥។

00867434

មេធាវីការពារក្តី នួន ជា មានពេលរហូតដល់ទៅបីឆ្នាំដើម្បីធ្វើការពិនិត្យមើលសំណុំរឿងក្នុងអំឡុងពេលនៃការស៊ើបអង្កេត[២៨]។

**២.៤. ក្រុមមេធាវីការពារក្តី អៀង សារី ស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការ ជាសាធារណៈផ្សព្វផ្សាយលើការអនុវត្តនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស**

១០. ក្រុមមេធាវីការពារក្តី អៀង សារី ក៏បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបើកសវនាការជាសាធារណៈដើម្បីស៊ើបអង្កេតលើការចោទប្រកាន់លើបែបបទអនុវត្តរបស់ ក.ស.ច.ស នៅក្នុងការស្តាប់ចម្លើយសាក្សីដោយពុំមានការថតខ្សែអាត់សម្លេង និងដើម្បីស៊ើបអង្កេតលើផលប៉ះពាល់ដែលបែបបទអនុវត្តទាំងនេះអាចកើតមានលើចម្លើយរបស់សាក្សីដែលបានថតខ្សែអាត់សម្លេង និងលើសក្ខីកម្មនៅអំឡុងពេលធ្វើសវនាការជំនុំជម្រះក្តី។ ក្រុមមេធាវីការពារក្តី អៀង សារី បានអះអាងថាខ្លួនបានរកឃើញករណីចំនួន ១២ លើកបន្ថែមទៀត ដែលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានស្តាប់ចម្លើយសាក្សីដោយពុំមានការថតខ្សែអាត់សម្លេងជាមុន[២៩] ហើយបានចោទប្រកាន់ថា ការអនុវត្តបែបនេះផ្ទុយនឹងវិធានផ្ទៃក្នុង ជាពិសេសវិធាន ២៥ ដែលតម្រូវឱ្យមានការថតសម្លេង ឬរូបភាពទុកជាផ្លូវការលើរាល់ការស្តាប់ចម្លើយសាក្សីទាំងអស់[៣០]។ ប្រសិនបើពុំមានការថតទុកទាំងស្រុងលើការស្តាប់ចម្លើយសាក្សីទាំងអស់នោះទេ ជនជាប់ចោទពុំមានលទ្ធភាពពិនិត្យភស្តុតាងដាក់បន្ទុកលើខ្លួន ឬពុំអាចការពារដោយត្រឹមត្រូវបានទេ ដែលវាផ្ទុយនឹងសិទ្ធិជាមូលដ្ឋានក្នុងការទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនជាប់ចោទ[៣១]។ ក្រុមមេធាវីការពារក្តី អៀង សារី ស្នើឡើងបន្ថែមទៀតថា បែបបទអនុវត្តដូចដែលបានចោទប្រកាន់ចំពោះការថតទុកតែមួយផ្នែកនោះ បង្ហាញឱ្យឃើញនូវគំរូជាទូទៅមួយនៃការស៊ើបសួរដោយលម្អៀង ដោយសារតែភាពទោរទន់របស់ចៅក្រម Marcel LEMONDE ក្នុងការស៊ើបអង្កេតតែទៅរកភស្តុតាងដាក់បន្ទុកជាជាងភស្តុតាងដោះបន្ទុក

[២៨] ក.ស.ព ឆ្លើយទៅនឹងសំណើសុំចូលរួមរបស់ នួន ជា ពីកថាខណ្ឌ ៨ ដល់កថាខណ្ឌ ១២។

[២៩] សំណើសុំលើកទីបួនរបស់ អៀង សារី កថាខណ្ឌ ១-៣។

[៣០] សំណើសុំលើកទីបួនរបស់ អៀង សារី កថាខណ្ឌ ១១-១២។

[៣១] សំណើសុំលើកទីបួនរបស់ អៀង សារី កថាខណ្ឌ ១៣។

00867435

ដូចដែលគេបានចោទប្រកាន់[៣២]។ សំណើសុំនេះត្រូវបានគាំទ្រដោយក្រុមមេធាវីការពារក្តី ខៀវ សំផន[៣៣]។

១១. ក្នុងការឆ្លើយតបទៅនឹងសំណើសុំនានាដែលបានដាក់ដោយមេធាវីការពារក្តី អៀង សារី សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើទាំងនោះ[៣៤]។ ចំពោះការចោទប្រកាន់ទាំង ១២ករណីដែលបានលើកឡើងដោយមេធាវីការពារក្តី អៀង សារី នោះគឺពាក់ព័ន្ធនឹងការមិនថតសម្លេងចំពោះសាក្សីដែលមិនត្រូវបានកោះហៅនៅឡើយដើម្បីមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ[៣៥]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងថា ការប្រព្រឹត្តរបស់ ក.ស.ច.ស មិនរំលោភបំពានវិធានផ្ទៃក្នុងទេ ជាពិសេសវិធាន ២៥[៣៦]។

## ៣. សម្អាងហេតុ

### ២.៤. ក្របខណ្ឌគតិយុត្ត

១២. វិធានផ្ទៃក្នុង អ.វ.ត.ក ចែងអំពីការប្រព្រឹត្តទៅនៃដំណើរការស៊ើបសួរនៅចំពោះមុខ អ.វ.ត.ក ដែលប្រមូលផ្តុំច្បាប់កម្ពុជាជាធរមាន និងអនុម័តយកតាមវិធាននានាដែលត្រូវបានបង្កើតឡើងនៅកម្រិតអន្តរជាតិបន្ថែមទៀតក្នុងករណីសមស្រប។ វិធានផ្ទៃក្នុង អ.វ.ត.ក រួមបញ្ចូលទាំងបទប្បញ្ញត្តិទាំងឡាយដែលមានគោលបំណងការពារភាពស្មោះត្រង់នៃកិច្ចស៊ើបសួរ និងភាពពិតជាក់ស្តែងនៃការថតសម្លេង សិទ្ធិទាំងឡាយរបស់គ្រប់ភាគីទាំងអស់ និងជាពិសេសសិទ្ធិទាំងឡាយរបស់

[៣២] សំណើសុំលើកទីបួនរបស់ អៀង សារី កថាខណ្ឌ ១២។

[៣៣] សំណើសុំចូលរួមរបស់ ខៀវ សំផន កថាខណ្ឌ ២-៤។

[៣៤] ចម្លើយរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសវនាការជាសាធារណៈ និងទទួលយកភស្តុតាងពាក់ព័ន្ធនឹងទម្លាប់អនុវត្តជាទូទៅ និងជាលក្ខណៈប្រព័ន្ធនៃការស្តាប់ចម្លើយដោយពុំមានការថតសម្លេង ឬ រូបភាព" ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឯកសារលេខ E241/2 (" ក.ស.ព ឆ្លើយតបទៅនឹងសំណើរបស់ អៀង សារី")។

[៣៥] ក.ស.ព ឆ្លើយតបទៅនឹងសំណើសុំទីបួនរបស់ អៀង សារី កថាខណ្ឌ ៣ និង ៤។

[៣៦] ក.ស.ព ឆ្លើយតបទៅនឹងសំណើសុំទីបួនរបស់ អៀង សារី កថាខណ្ឌ ២១ ដល់កថាខណ្ឌ ៣៩។

ជនជាប់ចោទ[៣៧]។ ក្នុងកិច្ចស៊ើបសួរទាំងមូល និងនៅក្នុងអំឡុងពេលសវនាការ នៅក្រោមលក្ខខណ្ឌមួយចំនួនវិធានផ្ទៃក្នុង អ.វ.ត.ក ក៏បានអនុញ្ញាតឱ្យជនជាប់ចោទ ព្រមទាំងភាគីផ្សេងៗទៀត អាចធ្វើការពិនិត្យ និងជំទាស់ទៅនឹងភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿងដែលគាំទ្រដល់ការចោទប្រកាន់នានាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងអាចស្នើសុំឱ្យមានការស៊ើបអង្កេតបន្ថែមទៀតផងដែរ។

១៣. នៅក្នុងសេចក្តីសម្រេចកាលពីមុន អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់អំពីក្របខណ្ឌគតិយុត្តដែលអាចអនុវត្តបានចំពោះដំណាក់កាលស៊ើបសួរ ក៏ដូចជាផលប៉ះពាល់នៃភាពមិនប្រក្រតីផ្នែកនីតិវិធីដែលបានចោទប្រកាន់ថាបានកើតឡើងនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះទៅលើកិច្ចដំណើរការនីតិវិធីសវនាការដែលកំពុងតែប្រព្រឹត្តទៅ[៣៨]។

១៤. អនុលោមតាមវិធាន ៥៥(៥) នៃវិធានផ្ទៃក្នុង បន្ទាប់ពីសហព្រះរាជអាជ្ញាដាក់សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេត "អាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិតដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេត

---

[37] វិធានផ្ទៃក្នុង ផ្នែក III(ខ)។ *សូមមើលផងដែរ* កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ("កិច្ចព្រមព្រៀង អ.វ.ត.ក") មាត្រា ១២ និងច្បាប់ស្តីពីការបង្កើតឱ្យ មានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាល នៃកម្ពុជាប្រជាធិបតេយ្យ ("ច្បាប់ អ.វ.ត.ក") មាត្រា ៣៣។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងការដាក់សម្ភារៈដើម្បីរៀបចំសវនាការ និងការដាក់អញ្ញត្រកម្ម ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E35/2 និងវិធាន ២១ នៃវិធានផ្ទៃក្នុង *ថែមទៀត* (ដែលចែងអំពីគោលការណ៍ ទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ជាមូលដ្ឋានពាក់ព័ន្ធទៅនឹងជនជាប់ចោទ)។

[38] *សូមមើល* សេចក្តីសម្រេចលើសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសម្លេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E142/3 ("សេចក្តីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសម្លេង")។ សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី សុំឱ្យមានសវនាការដេញដោលទៅលើការបំពេញកិច្ចស៊ើបសួរចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១១ ឯកសារ E71/1 ("សេចក្តីសម្រេចលើការបំពេញកិច្ចស៊ើបសួរ")។ *សូមមើលផងដែរ* សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ឯកសារ E116 ("សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ") និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា " សំណើសុំបកប្រែភាសាដើម្បីគាំទ្រដល់សំណើសុំ E142 របស់ជនជាប់ចោទ នួន ជា និងលិខិតរបស់ជនជាប់ចោទ អៀង សារី ផ្ញើមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១១ (ឯកសារ E142/1)" ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E142/2។

ត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ”[៣៩]។

### *៣.១.១ ការស្តាប់ចម្លើយជនរងគ្រោះ និងសាក្សីក្នុងដំណាក់កាលស៊ើបសួរ*

*១៥.* ចំណុចសំខាន់ជាមូលដ្ឋានមួយក្នុងដំណាក់កាលស៊ើបសួរ គឺការប្រមូលភស្តុតាង តាមរយៈការស្តាប់ចម្លើយជនរងគ្រោះ និងសាក្សី[៤០]។ ទោះបីសហចៅក្រមស៊ើបអង្កេតអាចស្តាប់ចម្លើយជនរងគ្រោះ ឬសាក្សីដោយផ្ទាល់ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអាចចេញដីកាបង្គាប់ឱ្យស៊ើបសួរជំនួស ដោយផ្តល់សិទ្ធិអំណាចដល់អ្នកស៊ើបអង្កេតពីការិយាល័យរបស់ខ្លួន ក្នុងការស្តាប់ចម្លើយ រួមទាំងវិធានការផ្សេងៗទៀតក្នុងការស៊ើបសួរ[៤១]។ ការស្តាប់ចម្លើយសាក្សីធ្វើឡើងដោយពុំមានវត្តមានភាគីនានាទេ[៤២] លើកលែងតែសហចៅក្រមស៊ើបអង្កេតប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការសម្រេចឱ្យមានការតទល់គ្នា។ អ្នកស៊ើបអង្កេតបំពេញការងារទៅតាមការណែនាំ និងការគ្រប់គ្រងរបស់សហចៅក្រមស៊ើបអង្កេត និងត្រូវរៀបរៀងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចស៊ើបសួររបស់ខ្លួន និងសេចក្តីសន្និដ្ឋាននៅក្នុងការអនុវត្តដីកាបង្គាប់ឱ្យស៊ើបសួរជំនួស[៤៣]។

*១៦.* មុនពេលស្តាប់ចម្លើយ សាក្សីត្រូវស្បថសិន[៤៤]។ អនុលោមតាមវិធាន ៥៥(៧) នៃវិធានផ្ទៃក្នុង រាល់ការស្តាប់ចម្លើយទាំងអស់ ត្រូវមានកំណត់ហេតុជាលាយលក្ខណ៍មួយ។ បន្ទាប់មក គេត្រូវអានកំណត់ហេតុជាលាយ

---

39 *សូមមើល* វិធាន ៥៣ និង ៥៥ នៃវិធានផ្ទៃក្នុង។ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ៥។ និងច្បាប់ អ.វ.ត.ក មាត្រា ២៣ថ្មី។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៧។

៤០ វិធាន ៥៥(ក) នៃវិធានផ្ទៃក្នុង; *សូមមើលផងដែរ* វិធាន ៦០(១) នៃវិធានផ្ទៃក្នុង។

៤១ វិធាន ៦២ នៃវិធានផ្ទៃក្នុង; *សូមមើលផងដែរ* វិធាន ១៤(៥) និង៥៥(៩) នៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៣១, ១៧៣-១៧៤។ អនុលោមតាមវិធាន ១៦ នៃវិធានផ្ទៃក្នុង អ្នកស៊ើបអង្កេតត្រូវទទួលនីតិសម្បទាពីក្រសួងយុត្តិធម៌កម្ពុជា និងស្បថនៅចំពោះមុខអង្គជំនុំជម្រះនៃ អ.វ.ត.ក។

៤២ វិធាន ៦០(២) នៃវិធានផ្ទៃក្នុង៖ “លើកលែងតែការធ្វើតទល់គ្នា សហចៅក្រមស៊ើបអង្កេត ឬ អ្នកទទួលសិទ្ធិត្រូវស្តាប់ចម្លើយសាក្សី ដោយគ្មានវត្តមានជនត្រូវចោទ ភាគីដទៃទៀត ឬមេធាវី នៅទីកន្លែងណាដែលអាចរក្សាការសម្ងាត់បាន”; *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៥៣។

៤៣ វិធាន ៦២(៣)(ក) នៃវិធានផ្ទៃក្នុង។ ខណៈដែលបញ្ញត្តិនេះតម្រូវឱ្យអនុវត្តតាមវិធាន ៥១(៨) នៃវិធានផ្ទៃក្នុង ដែលកំណត់ឱ្យសហចៅក្រមស៊ើបអង្កេតត្រូវ “ធ្វើរបាយការណ៍ពីរយៈពេលសម្ភាសន៍ និង រយៈពេលសម្រាកចន្លោះពេលសម្ភាសន៍” ឯកសារយោងចំពោះបទប្បញ្ញត្តិទាំងនេះគឺកម្រិតតែភាពពាក់ព័ន្ធទេ ដោយសារវាពាក់ព័ន្ធតែនឹងនីតិវិធីសម្រាប់ធ្វើរបាយការណ៍ស្តីពីការឃាត់ខ្លួនបុគ្គលណាម្នាក់នៅនគរបាលយុត្តិធម៌តែប៉ុណ្ណោះ។ *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៧៨។

៤៤ វិធាន ២៤ នៃវិធានផ្ទៃក្នុង; *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ១៥៤។

00867438

លក្ខណ៍អក្សរឱ្យអ្នកផ្តល់ចម្លើយស្តាប់ ហើយគាត់ត្រូវបញ្ជាក់ពីភាពសុក្រឹតនៃខ្លឹមសារនៃកំណត់ហេតុនោះ ដោយមានចុះហត្ថលេខា ឬ ស្នាមមេដៃលើគ្រប់ទំព័រទាំងអស់។ បន្ទាប់មកគេត្រូវបញ្ចូលកំណត់ហេតុនេះទៅក្នុងសំណុំរឿង ហើយភាគីទាំងអស់អាចប្រើប្រាស់កំណត់ហេតុនោះបាន។ តាមការសង្កេតរបស់អង្គជំនុំជម្រះ កំណត់ហេតុជាលាយលក្ខណ៍អក្សររបស់សហចៅក្រមស៊ើបអង្កេត ឬមន្ត្រីទទួលសិទ្ធិ ពុំមែនជាកំណត់ហេតុដែលកត់ត្រាពាក្យសំដីទាំងស្រុងទេ តែជារបាយការណ៍សង្ខេបនៃការស្តាប់ចម្លើយដែលផ្តល់ដោយជនរងគ្រោះ ឬសាក្សី ដែលត្រូវធ្វើឱ្យបានពេញលេញ ឬមិនលម្អៀងជាទីបំផុត[៤៥]។

១៧. ទោះបីវិធាន ២៥ នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យមានការថតសំឡេង ឬរូបភាពនៃការស្តាប់ចម្លើយក៏ដោយ តែអង្គជំនុំជម្រះបានបញ្ជាក់ច្បាស់រួចមកហើយថា ការថតសំឡេង ឬរូបភាព ពុំមែនជាលក្ខខណ្ឌចាំបាច់ដែលតម្រូវដោយច្បាប់ទេ[៤៦]។ វិធាន ២៥ នៃវិធានផ្ទៃក្នុង បានតម្រូវដោយដាក់លាក់ឱ្យមានការថតសំឡេង ឬរូបភាព តែចំពោះការសួរចម្លើយជនសង្ស័យ ឬជនត្រូវចោទតែប៉ុណ្ណោះ។ ការអនុវត្តបែបនេះគឺស្របទៅនឹងវិធាននីតិវិធីដែលបង្កើតឡើងនៅឯកម្រិតតុលាការអន្តរជាតិ ដែលការថតសំឡេង ឬរូបភាពនៃការស្តាប់ចម្លើយសាក្សីក្នុងដំណាក់កាលស៊ើបសួរពុំមែនជាលក្ខខណ្ឌចាំបាច់ដែលតម្រូវដោយច្បាប់ទេ[៤៧]។ ការការពារដោយនីតិវិធីជាធរមាននៅ អ.វ.ត.ក ក្នុងដំណាក់កាលស៊ើបសួរ កើតចេញពីឯករាជភាព និងភាពមិនលម្អៀងរបស់សហចៅក្រមស៊ើបអង្កេត ដែលស្ថាប័នមួយនេះពុំមាននៅតាមតុលាការដែលមានលក្ខណៈអន្តរជាតិនោះទេ។ ផ្ទុយទៅវិញ ការស៊ើបសួរនៅតុលាការទាំងនោះត្រូវបានធ្វើឡើងដោយភាគីក្នុងកិច្ចដំណើរការនីតិវិធី[៤៨]។

[៤៥] សេចក្តីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងរបស់ ក.ស.ច.ស, កថាខណ្ឌ ១១។

[៤៦] សេចក្តីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងរបស់ ក.ស.ច.ស, កថាខណ្ឌ ៦។ ជាងនេះទៀតមានការបញ្ជាក់ច្បាស់ហើយពីអំណានបែបទូលំទូលាយចំពោះវិធាន ២៥ នៃវិធានផ្ទៃក្នុងជាបីភាសាដែលថា ពីកថាខណ្ឌ ១ ដល់ ៣ នៃវិធាននេះអនុវត្តចំពោះការសួរចម្លើយជនសង្ស័យ ឬជនត្រូវចោទដែលបានធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ឬ ក.ស.ច.ស ខណៈដែលកថាខណ្ឌ ៤ អនុវត្តចំពោះការសួរ "មនុស្សផ្សេងទៀត" រួមមាន សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលមុនសវនាការ ចំណែកឯកថាខណ្ឌ ៥ អនុវត្តចំពោះការសួរសំណួរដល់អ្នកដែលត្រូវបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។

[៤៧] *សូមមើល* វិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICTY, វិធាន ៤៣ (ដែលអនុញ្ញាតឱ្យមានការថតសំឡេង ឬរូបភាពតែក្នុងករណីពាក់ព័ន្ធនឹងការសួរចម្លើយជនសង្ស័យប៉ុណ្ណោះ); *សូមមើលផងដែរ* វិធាននីតិវិធី និងភស្តុតាងនៃតុលាការ ICC, វិធាន ១១២(៤) និង (៥) ដែលចែងថា៖ "[...] ជាពិសេសនៅពេលប្រើនីតិវិធីបែបនេះអាចជួយកាត់បន្ថយដល់ការស្លុតស្មារតីនៃជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទ ឬយេនឌ័រ កុមារ ឬជនពិការក្នុងការផ្តល់ភស្តុតាង"។ ដោយសារមានសំណើពីសហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះ ក៏អាចបង្គាប់ឱ្យថតសំឡេង ឬរូបភាពនៃការសួរសំណួរដល់ជនណាម្នាក់បាន នៅពេលមានការបង្ហាញថា នេះជាឱកាសតែមួយក្នុងការផ្តល់សក្ខីកម្ម ឬចម្លើយ ពីសាក្សីណាម្នាក់ដែលមិនអាចមានវត្តមាន សម្រាប់គោលបំណងនៃសវនាការបាន)។

[៤៨] ជាងនេះទៀត ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ក៏មិនបានតម្រូវ ឬកំណត់ឱ្យមានការថតសំឡេង ឬរូបភាពនៃការសួរចម្លើយជនសង្ស័យ និងជនត្រូវចោទ ឬ ស្តាប់ចម្លើយជនរងគ្រោះឬសាក្សីទេ។ ក្នុងករណីទាំងនោះ គេតម្រូវឱ្យ

### *៣.១.២ ការចូលមើលសំណុំរឿងដោយភាគី*

១៨. ក្នុងសំណុំរឿង មានទាំងភស្តុតាងដាក់បន្ទុក និងដោះបន្ទុក ដែលបានប្រមូលក្នុងអំឡុងពេលស៊ើបសួរ ហើយពាក់ព័ន្ធទៅនឹងការចោទប្រកាន់ប្រឆាំងជនជាប់ចោទ រួមមានកំណត់ហេតុនៃកិច្ចស៊ើបសួរដែលត្រូវបានធ្វើឡើងក្នុងពេលស៊ើបសួរ កំណត់ហេតុជាលាយលក្ខណ៍អក្សរ និងការថតសំឡេង ឬរូបភាពនៃការស្តាប់ចម្លើយ រួមទាំងពាក្យសុំដែលភាគីនានានៃកិច្ចដំណើរការនីតិវិធីបានស្នើ។ បន្ទាប់ពីទទួលការចោទប្រកាន់ ជនសង្ស័យ និងមេធាវីរបស់ខ្លួនបានទទួលការអនុញ្ញាតឲ្យចូលមើលសំណុំរឿងបាន។ ភាគីទាំងអស់អាចចូលមើលសំណុំរឿងបានគ្រប់ពេល[៤៩]។

១៩. នៅពេលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា រាល់សម្ភារៈពាក់ព័ន្ធទាំងអស់ដែលបានប្រមូលក្នុងពេលស៊ើបសួរនៅក្នុងសំណុំរឿងផ្តល់នូវមូលដ្ឋានគ្រប់គ្រាន់សម្រាប់ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះហើយនោះ សំណុំរឿងនោះត្រូវបញ្ជូនទៅឲ្យអង្គជំនុំជម្រះសាលាដំបូង ហើយជនជាប់ចោទត្រូវបញ្ជូនទៅជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ[៥០]។

### *៣.១.៣ ការជំទាស់ទៅនឹងប្រក្រតីភាពនៃដំណាក់កាលស៊ើបសួរ*

២០. វិធានផ្ទៃក្នុងបានផ្តល់ឱកាសជាច្រើនដល់ភាគីក្នុងការវាយតម្លៃទៅលើព័ត៌មាននានាដែលបានប្រមូលក្នុងពេលស៊ើបសួរ។ ក្នុងដំណាក់កាលស៊ើបសួរ ភាគីអាចស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬបំពេញកិច្ចស៊ើបសួរ ដែលខ្លួនយល់ថា មានប្រយោជន៍សម្រាប់ដំណើរការនៃកិច្ចស៊ើបសួរបាន[៥១]។ ជាងនេះទៀត ក្នុងពេលស៊ើបសួរ ភាគីក៏អាចជំទាស់ទៅនឹងសុពលភាពនៃផ្នែកណាមួយនៃកិច្ចដំណើរការនីតិវិធីបាន រួមមានការបំពេញកិច្ចស៊ើបសួរ និងស្នើសុំឲ្យមោឃភាពកិច្ចស៊ើបសួរនោះ។ ការប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះប្រឆាំងនឹងដីកា ឬសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត រួមទាំងសេចក្តីសម្រេចបញ្ចប់កិច្ចស៊ើបសួរ និងការបញ្ជូនសំណុំរឿង រួមជាមួយដីកាដំណោះស្រាយ ទៅឲ្យអង្គជំនុំជម្រះសាលាដំបូងដើម្បីជំនុំជម្រះ បានបង្កើតជាការការពារផ្នែកនីតិវិធីបន្ថែមទៀត[៥២]។

---

មានតែកំណត់ហេតុជាលាយលក្ខណ៍អក្សរទេ; *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ៩៣, ១១៥ និង ២៤២។

[៤៩] វិធាន ៥៥(៦) នៃវិធានផ្ទៃក្នុង។ ក្នុងដំណាក់កាលសវនាការ ភាគីនៅតែអាចចូលមើលសំណុំរឿងបាន (*សូមមើល* វិធាន ៨៦ នៃវិធានផ្ទៃក្នុង)។

[៥០] វិធាន ៦៧ និង ៦៩ នៃវិធានផ្ទៃក្នុង; *សូមមើលផងដែរ* វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង។

[៥១] វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង។

[៥២] *សូមមើល* វិធាន ៦៦, ៦៧, ៧៣, ៧៤ និង ៧៦ នៃវិធានផ្ទៃក្នុង។

00867440

២១. ទាក់ទិននឹងការការពារផ្នែកនីតិវិធីជាមូលដ្ឋានដែលមានក្នុងដំណាក់កាលស៊ើបសួរនោះ វិធាន ៧៦(៦) នៃវិធានផ្ទៃក្នុងចែងថា៖ "ដីកាដំណោះស្រាយ [នៅពេលចូលជាស្ថាពរ] ត្រូវកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ"។ ហេតុនេះ អនុលោមតាមវិធាននេះ "គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អង្គជំនុំជម្រះតុលាការកំពូលឡើយ"[៥៣]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងអាចត្រឹមតែពិចារណាទៅលើរំលោភភាពនីតិវិធីដែលត្រូវធ្វើ "បន្ទាប់ពីមានដីកាដំណោះស្រាយ" ប៉ុណ្ណោះ[៥៤]។

២២. ហេតុនេះ ក្របខណ្ឌច្បាប់នៅ អ.វ.ត.ក ពុំបានចែងអំពីការពិនិត្យឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូងអំពីភាពត្រឹមត្រូវផ្នែកនីតិវិធីនៃកិច្ចស៊ើបសួរក្រោយពេលទទួលបានសំណុំរឿងក្តីនោះទេ[៥៥]។ អង្គជំនុំជម្រះក៏បានបញ្ជាក់ផងដែរថា អង្គជំនុំជម្រះពុំមែនជាស្ថាប័នទទួលបណ្តឹងឧទ្ធរណ៍ ឬពិនិត្យឡើងវិញចំពោះវិធានការនានាដែលស្ថាប័នស៊ើបអង្កេតបានធ្វើក្នុងដំណាក់កាលស៊ើបសួរនោះទេ[៥៦]។ ជាងនេះទៀត ដោយសារវិធានការទាំងនោះត្រូវបានរៀបចំក្រោមការគ្រប់គ្រងរបស់សហចៅក្រមស៊ើបអង្កេត ដោយមានការការពារចំពោះយថាភាព និងភាពជឿជាក់បាននៃវិធានការទាំងនោះហើយនោះ ចម្លើយសាក្សី ជាពិសេសចម្លើយនានាដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ដែលបានស្តាប់ដោយ ក.ស.ច.ស ក្នុងពេលស៊ើបសួរ ត្រូវបានសន្មតថាអាចជឿជាក់បាន[៥៧]។ គេអាចជំទាស់នឹងការសន្មតបែបនេះបាន នៅពេលភាគីផ្តល់នូវសំអាងហេតុពេញលេញ ដោយមានភស្តុតាងច្បាស់លាស់គាំទ្រដែលថា ចម្លើយដែលបានលើកឡើងនោះពុំអាចជឿជាក់បាន ឬមិនសុក្រឹត្យតែប៉ុណ្ណោះ។

## ៣.២ <u>បទដ្ឋាននៃការពិនិត្យឡើងវិញលើការជំទាស់ផ្នែកនីតិវិធីចំពោះកិច្ចស៊ើបសួរ</u>

២៣. ភាគីបានលើកឡើងនូវការចោទប្រកាន់ជាក់លាក់មួយចំនួនពីភាពមិនប្រក្រតី និង ការមិនគោរពវិធានបញ្ញត្តិ

---

[៥៣] វិធាន ៧៦(៦) នៃវិធានផ្ទៃក្នុង; *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៥៦ និង សេចក្តីសម្រេចលើការរៀបចំកិច្ចស៊ើបសួរ និង សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ ១៥ និង ១៧។

[៥៤] វិធាន ៨៩(១)(គ) នៃវិធានផ្ទៃក្នុង; *សូមមើលផងដែរ* សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ ១៥។

[៥៥] សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ ១៧។

[៥៦] សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ ១៨។

[៥៧] សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២, ឯកសារលេខ E185, កថាខណ្ឌ ២០។

ដែលត្រូវបានចោទប្រកាន់ថាបានកើតឡើងក្នុងពេលស្តាប់ចម្លើយសាក្សីជាក់លាក់ដោយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ក្នុងដំណាក់កាលមុនពេលសវនាការ។ ការចោទប្រកាន់ទាំងនេះរួមមានការចោទប្រកាន់ថា អ្នកស៊ើបអង្កេតបានរៀបចំការស្តាប់ចម្លើយសាក្សីជាមុន ឬ ពុំមានថតសំឡេងនៃការស្តាប់ចម្លើយឱ្យបានពេញលេញ។

២៤. កិច្ចដំណើរការនីតិវិធីក្នុងពេលសវនាការ ដែលក្នុងនោះសំណុំរឿង ០០២/០១ កើតមានបន្ទាប់ពីកិច្ចស៊ើបសួរដែលមានរយៈពេលវែង មានបំណងពិនិត្យទៅលើបញ្ហាសំខាន់ៗដែលពាក់ព័ន្ធនឹងអង្គហេតុដែលមានក្នុងដីកាដំណោះស្រាយ និងការចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ចោទ[៥៨]។ ភាគីទាំងអស់ រួមទាំងមេធាវីការពារក្តីផង ក៏មានឱកាសក្នុងការសួរតទល់សាក្សីដែលអង្គជំនុំជម្រះកោះហៅឱ្យមកផ្តល់សក្ខីកម្មដែរពាក់ព័ន្ធនឹងភាពខ្វះចន្លោះរវាងភស្តុតាងផ្ទាល់មាត់ និង ចម្លើយពីមុនរបស់ខ្លួន នៅពេលដែលចំណុចនេះពាក់ព័ន្ធនឹងភស្តុតាងពេលសវនាការ[៥៩]។

២៥. នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលក្នុងប្រទេសវិញ ជាទូទៅ សាក្សីដែលបានស្តាប់ចម្លើយក្នុងដំណាក់កាលស៊ើបសួរពុំត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មក្នុងសវនាការទាំងអស់គ្នាទេ។ ការដែលថា សាក្សីមួយចំនួនធំត្រូវបានកោះហៅមកផ្តល់សក្ខីកម្មក្នុងពេលសវនាការបច្ចុប្បន្ន បង្ហាញមួយផ្នែកនូវភាពចាំបាច់ក្នុងការធានាថា បន្ទាប់ពីដំណាក់កាលស៊ើបសួរដោយសម្ងាត់នោះ សាធារណជនមានឱកាសក្នុងការស្តាប់សក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសាលាដំបូងក៏កត់សម្គាល់ផងដែរថា ទាំង ក.ស.ច.ស និងអង្គបុរេជំនុំជម្រះ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍បានសម្រេចថា ការសួរដេញដោលសាក្សីអាចធ្វើឡើងក្នុងពេលសវនាការបាន ដោយតម្រូវឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យភាគីមានឱកាសសមស្របក្នុងការសួរដេញដោល[៦០]។

២៦. ផ្ទុយពីទម្លាប់អនុវត្តធម្មតានៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងដោយសារពេលវេលាមានកំណត់ក្នុងពេលស៊ើបសួរនោះ បញ្ហាមួយដែលត្រូវឱ្យអង្គជំនុំជម្រះពិចារណានៅពេលសវនាការគឺផលប៉ះពាល់ពីការសម្រេចរបស់ ក.ស.ច.ស ពាក់ព័ន្ធនឹងសាក្សីមួយចំនួនដែលត្រូវបានតវ៉ា។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អង្គជំនុំជម្រះអាចពិចារណាតែលើការជំទាស់ជាក់លាក់ និងមានសំអាងហេតុគ្រប់គ្រាន់ចំពោះសក្ខីកម្មសាក្សីនៅពេលសវនាការតែប៉ុណ្ណោះ នៅពេលមានការចោទប្រកាន់ពីភាពខ្វះចន្លោះពាក់ព័ន្ធរវាង

---

៥៨ *សូមមើលផងដែរ* ប្រតិចារឹក, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២, ទំព័រ ៣៦-៣៧ និង ៤២-៤៣ (ភាសាអង់គ្លេស)។

៥៩ សេចក្តីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងរបស់ ក.ស.ច.ស, កថាខណ្ឌ ១៣; *សូមមើលផងដែរ* សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, កថាខណ្ឌ ១៩។

៦០ *ឧទាហរណ៍* សាលដីកាលើបណ្តឹងឧទ្ធរណ៍ និងសេចក្តីសន្និដ្ឋានបន្ថែមជំទាស់នឹងដីកាសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើសំណើរបស់ នួន ជា សុំឱ្យស្តាប់ចម្លើយមួយចំនួន (D318, D319, D320, D336, D338, D339 & D340), ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១២, ឯកសារលេខ D375/1/8, កថាខណ្ឌ ៥៧។

កំណត់ហេតុជាលាយលក្ខណ៍អក្សរ និងខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយក្នុងដំណាក់កាលស៊ើបសួរ។ ការនេះតម្រូវឱ្យភាគីបង្ហាញថា ខ្លួនពុំមានឱកាសក្នុងការស្វែងរកភាពមិនប្រក្រតីមុនពេលសវនាការចាប់ផ្តើម ហើយថា ភាពខ្វះចន្លោះទាំងនោះមានភាពពាក់ព័ន្ធទៅនឹងការវាយតម្លៃភស្តុតាងនៃឯកសារទាំងនោះ ឬចាំបាច់ដែលត្រូវការពារភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី[៦១]។ ភាគីត្រូវទទួលបានឱកាសដោយផ្ទាល់ក្នុងការវាយតម្លៃទៅលើភស្តុតាងដែលបានលើកឡើងក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី ជាពិសេសនៅពេលវាមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងទង្វើ និងការប្រព្រឹត្តរបស់ជនជាប់ចោទ នៅពេលដែលឱកាសនេះត្រូវបានរារាំង ឬបដិសេធក្នុងដំណាក់កាលមុនសវនាការ[៦២]។

២៧. ទោះជាយ៉ាងណាក្តី ដោយសារភាពខ្វះចន្លោះនានាដែលបានចោទប្រកាន់ពុំមានទម្ងន់លើអង្គហេតុដែលបានលើកឡើងក្នុងពេលសវនាការ ឬភាពជឿជាក់បានរបស់សាក្សីនោះ រាល់ការជំទាស់ទៅនឹងចម្លើយសាក្សីមិនត្រូវបានទទួលយកក្នុងដំណាក់កាលសវនាការនេះទេ។

២៨. នៅពេលមានការធានាត្រឹមត្រូវ អង្គជំនុំជម្រះនឹងពិចារណាទៅលើភាពមិនប្រក្រតីនានាក្នុងពេលស្តាប់ចម្លើយសាក្សីដែលបានធ្វើឡើងក្នុងដំណាក់កាលស៊ើបសួរ រួមទាំងភាពខ្វះចន្លោះនានារវាងការស្តាប់ចម្លើយទាំងនេះ និងសក្ខីកម្មរបស់ពួកគេក្នុងពេលសវនាការ នៅពេលសម្រេចអំពីតម្លៃ និងទម្ងន់នៃភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

---

៦១ សេចក្តីសម្រេចលើកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងរបស់ ក.ស.ច.ស, កថាខណ្ឌ ៧, ១២ និង ១៤ (ដែលបានបញ្ជាក់បន្ថែមថា អង្គជំនុំជម្រះសាលាដំបូងនឹងទទួលយកការចោទប្រកាន់ពីភាពមិនស៊ីសង្វាក់គ្នាតែក្នុងករណីដែលការចោទប្រកាន់ទាំងនេះត្រូវបានបង្ហាញដោយភាពជាក់លាក់ពេញលេញប៉ុណ្ណោះ និងពាក់ព័ន្ធចំពោះភាពខ្វះចន្លោះនៃខ្លឹមសារដែលមានភាពពាក់ព័ន្ធច្បាស់លាស់ទៅនឹងសវនាការ ហើយថា ភាគីដែលបានលើកឡើងនូវការជំទាស់បែបនេះមានបន្ទុកត្រូវបង្ហាញឱ្យបានច្បាស់ពីភាពខ្វះចន្លោះដែលបានចោទប្រកាន់ និងជូនដំណឹងជាមុនឱ្យបានទាន់ពេលវេលាដល់អង្គជំនុំជម្រះ និងភាគីផ្សេងទៀត និងឯកសារដែលពាក់ព័ន្ធនឹងការភាពខ្វះចន្លោះទាំងនោះ)។ *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខ្លួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២, ឯកសារលេខ E116/1/7, កថាខណ្ឌ ៣១ (ក្នុងការពិភាក្សាពីភាពដាច់ពីគ្នាដាច់ខាតនៃសមត្ថកិច្ចតុលាការនៅ អ.វ.ត.ក ពាក់ព័ន្ធនឹងការចោទប្រកាន់ពីការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះនោះ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញថា ស្ថាប័នតុលាការណាដែលបានទទួលរឿងក្តីនោះ "គ្មានជម្រើសអ្វីក្រៅតែពីការអនុវត្តអំណាចដែលមានដើម្បីធានាថា កិច្ចដំណើរការនីតិវិធីស្របទៅនឹងបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ដោយមិនគិតថា រឿងរ៉ាវដែលត្រូវបានចោទប្រកាន់អំពីការជ្រៀតជ្រែកបានកើតឡើងនៅពេលណានោះទេ")។

៦២ នៅក្នុងសេចក្តីសម្រេចមួយពីមុន អង្គជំនុំជម្រះនេះបានទទួលស្គាល់រួចហើយនូវរបៀបផ្តល់ឱកាសសម្រាប់មេធាវីការពារក្តី ក្នុងការជំទាស់ទៅនឹងភស្តុតាងបែបនេះ គឺជាលក្ខខណ្ឌមួយសម្រាប់ទទួលយកភស្តុតាងនេះនៅពេលសវនាការ; *សូមមើល* សេចក្តីសម្រេចលើការទទួលយកចម្លើយសាក្សី, កថាខណ្ឌ ២១-២៥ (បានបង្ហាញថា នៅពេលពុំមានសក្ខីកម្មផ្ទាល់មាត់ និងឱកាសក្នុងការតទល់ពីតម្លៃជាភស្តុតាង ហើយក្នុងកាលៈទេសៈជាច្រើន ទម្ងន់ដែលផ្តល់ឱ្យភស្តុតាងបែបនេះអាចនឹងត្រូវកម្រិតដែរ); *សូមមើលផងដែរ* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា ២៨៧។

00867443

## ៣.៣. ការវាយតម្លៃលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី

### ៣.៣.១. ការដាក់សំណើសុំទាន់ពេលវេលា

២៩. សាក្សីនីមួយៗ ត្រូវបានស្តាប់ចម្លើយនៅក្នុងដំណាក់កាលស៊ើបសួររួចរាល់អស់ហើយ។ សាក្សី ភី ភួន ត្រូវបានអ្នកស៊ើបអង្កេត ក.ស.ច.ស ស្តាប់ចម្លើយនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ និងនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយទាំងនេះ ត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៨ និងនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៩ ដោយឡែកពីគ្នា[៦៣]។ ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយទាំងនេះត្រូវបានថតទុក និងដាក់បញ្ចូលនៅក្នុងសំណុំរឿងនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៨ និងនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៩ ដោយឡែកពីគ្នា[៦៤]។ សាក្សី អឿន តាន ត្រូវបានស្តាប់ចម្លើយនៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ និងនៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយទាំងនេះត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ និងនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩ ដោយឡែកពីគ្នា[៦៥]។ ខ្សែអាត់សម្លេងនៃការ

---

[៦៣] កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរលើសាក្សី ភី ភួន ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារលេខ E3/24។ កំណត់ហេតុនៃជាភាសាខ្មែរ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៨ ចំណែក កំណត់ហេតុជាភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០៨។ លើសពីនេះ ដំបូងឡើយ កំណត់ហេតុជាភាសាបារាំង ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ២៧ ខែ មេសាឆ្នាំ ២០១០ ហើយបានចេញចេញម្តងទៀត ក្រោយពីមានការកែប្រែនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។ *សូមមើលផងដែរ* កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍ អក្សរលើសាក្សី ភី ភួន ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារលេខ E3/63។

[៦៤] ការស្តាប់ចម្លើយសាក្សី ភី ភួន ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧ ឯកសារលេខ D91/10R។ ប្រតិចារឹកជាភាសាខ្មែរទាំងមូលនៃខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយនេះ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចំណែកប្រតិចារឹកនេះជាភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១។ *សូមមើលផងដែរ* ប្រតិចារឹកនៃការស្តាប់ចម្លើយសាក្សី ភី ភួន ដែលមានការថតសម្លេង ឯកសារលេខ D91/10.1។ *សូមមើលផងដែរ* ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី ភី ភួន ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ឯកសារលេខ D107/3R។ ប្រតិចារឹកនៃខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយនេះមួយផ្នែក មានស្រាប់ហើយក្នុងពេលបច្ចុប្បន្នេះ។ *សូមមើល* ប្រតិចារឹកនៃការស្តាប់ចម្លើយដែលមានការថតទុកជាមួយសាក្សី ភី ភួន ឯកសារលេខ D107/3.1។

[៦៥] កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរលើសាក្សី អឿន តាន ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារលេខ E3/33។ កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរលើសាក្សី អឿន តាន ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩ ឯកសារលេខ D200/8។ កំណត់ហេតុជាភាសាបារាំង និងខ្មែរ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ចំណែកឯកកំណត់ហេតុជាភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨។

ស្តាប់ចម្លើយនាថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ត្រូវបានថតទុក និងដាក់បញ្ចូលនៅក្នុងសំណុំរឿងនៅថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨[៦៦]។ ហើយសាក្សីចុងក្រោយគឺសាក្សី នង សុផង់ ត្រូវបានស្តាប់ចម្លើយនៅថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ និងនៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយទាំងនេះត្រូវបានដាក់ចូលនៅក្នុងសំណុំរឿងនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៩ និងនៅថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១០ ដោយឡែកពីគ្នា[៦៧]។ ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយនាថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿងនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩[៦៨]។

៣០. នៅក្នុងអំឡុងពេលសវនាការបឋមពីថ្ងៃទី ២៧ ដល់ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានពិភាក្សាជាមួយភាគីអំពីបញ្ជីបុគ្គលទាំងឡាយ ដែលត្រូវបានស្នើសុំឱ្យស្តាប់ចម្លើយក្នុងអំឡុងពេលធ្វើសវនាការ ហើយនៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានចេញបញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវស្តាប់ចម្លើយនៅក្នុងពេលធ្វើសវនាការ។ បញ្ជីនេះបានដាក់បញ្ចូល ភី ភួន អឿន តាន និង នង សុផង់ ជាសាក្សី[៦៩]។

៣១. យោងតាមក្រុមមេធាវីការពារក្តី អៀង សារី និងក្រុមមេធាវីការពារក្តី ខៀវ សំផន ក្រុមមេធាវីការពារក្តីទាំងពីរក្រុមបានដឹងអំពីបញ្ហាភាពមិនប្រក្រតីដែលទំនងអាចកើតមានឡើងនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី ភី ភួន អឿន តាន និង នង សុផង់ ដែល

---

[៦៦] ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ D107/2R។ ប្រតិចារឹកនៃខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយនេះមួយផ្នែក មានស្រាប់ហើយក្នុងពេលបច្ចុប្បន្នេះ។ *សូមមើល* ប្រតិចារឹកនៃការស្តាប់ចម្លើយសាក្សី អឿន តាន ត្រង់ផ្នែកខ្លះ ឯកសារលេខ D107/2.1។ ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩។ *សូមមើល* ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៩ D200/8R។

[៦៧] កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរលើសាក្សី នង សុផង់ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារលេខ E3/64។ កំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរលើសាក្សី នង សុផង់ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩ ឯកសារលេខ E3/67។ កំណត់ហេតុជាភាសាខ្មែរ និងអង់គ្លេស ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩ ចំណែកឯកកំណត់ហេតុជាភាសាបារាំងត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០០៩។

[៦៨] ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩ D200/3R។ ប្រតិចារឹកនៃខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយផ្នែកខ្លះមួយចំនួន មានស្រាប់ហើយក្នុងពេលបច្ចុប្បន្នេះ។ ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៩។ *សូមមើល* ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៩ D200/9R។

[៦៩] ឧបសម្ព័ន្ធ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២ ចុះថ្ងៃទី ២៥ ខែ តុលាឆ្នាំ ២០១១ ឯកសារលេខ E131/1.1.។

ធ្វើឡើងដោយ ក.ស.ច.ស ក្នុងពេលដែលខ្លួនបានត្រៀមរៀបចំស្តាប់សក្ខីកម្មសាក្សីទាំងនេះ។ ក្រុមមេធាវីការពារក្តីបានដឹងបញ្ហានេះបន្ទាប់ពីរយៈពេលជាច្រើនឆ្នាំក្រោយពេលការស្តាប់ចម្លើយទាំងនេះបានធ្វើឡើង និងក្រោយពេលកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ ព្រមទាំងខ្សែអាត់សម្លេង ត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ដើម្បីផ្តល់លទ្ធភាពឱ្យភាគីទាំងអស់បានពិនិត្យមើល និងរយៈពេលជាច្រើនខែក្រោយពេលចាប់ផ្តើមសវនាការជំនុំជម្រះក្តី។ អង្គជំនុំជម្រះយល់ឃើញថា ការចោទប្រកាន់ទាំងនេះពុំបានធ្វើឡើងទាន់ពេលវេលា ហើយការពិតទៅ វាពិបាកក្នុងការធ្វើការវាយតម្លៃ ដោយសារតែពេលវេលាដែលបានកន្លងផុតទៅយូរបែបនេះ បានធ្វើឱ្យប៉ះពាល់ដល់ការចងចាំរបស់សាក្សីអំពីកាលៈទេសៈជាក់ស្តែងដែលបានកើតឡើងក្នុងពេលស្តាប់ចម្លើយពួកគេ[៧០]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា ក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន ខកខានពុំបានលើកបញ្ហានេះឡើងក្នុងដំណាក់កាលស៊ើបសួរ ឬលើកឱ្យបានទាន់ពេលវេលានៅក្នុងអំឡុងពេលនៃការចាប់ផ្តើមសវនាការជំនុំជម្រះក្តី។

### ៣.៣.២. ផលប៉ះពាល់នៃភាពមិនប្រក្រតីដែលបានចោទប្រកាន់លើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី

៣២. សាក្សី ភី ភួន បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងចាប់ពីថ្ងៃទី ២៥ ខែ កក្កដា ដល់ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០១២ សាក្សី អឿន តាន នៅអំឡុងថ្ងៃទី ១៣ ដល់ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ហើយ សាក្សី នង សុផង់ នៅថ្ងៃទី ២៩ ខែ សីហា និង នៅអំឡុងពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២។ នៅពេលចាប់ផ្តើមផ្តល់សក្ខីកម្មរបស់ខ្លួននោះ សាក្សីនីមួយៗបានបញ្ជាក់ថា ខ្លួនបានពិនិត្យមើលកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយមុនៗដែលបានធ្វើឡើងជាមួយនឹង ក.ស.ច.ស ហើយបានបញ្ជាក់អំពីភាពត្រឹមត្រូវនៃខ្លឹមសារទាំងនេះ[៧១]។ ភាគីទាំងអស់ រួមទាំងក្រុមមេធាវីការពារក្តី អៀង

[៧០] នៅពេលសួរដេញដោលនៅក្នុងពេលជំនុំជម្រះអំពីអនិយ័តភាពដែលអាចកើតមានក្នុងអំឡុងពេលនៃការស្តាប់ចម្លើយធ្វើឡើងដោយ ក.ស.ច.ស សាក្សី នង សុផង់ បានបញ្ជាក់ថា គាត់មិនអាចចាំបានច្រើនអំពីបញ្ហានេះទេ ដោយសារតែពេលវេលាបានកន្លងផុតយូរមកហើយ (ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ ទំព័រ ៦២)។

[៧១] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៦៩-៧២។ ប្រតិចារឹក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ៨-១០។ ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣២-៣៣។ បែបបទអនុវត្តនេះត្រូវបានអនុវត្តចំពោះគ្រប់សាក្សីទាំងអស់ដែលមកផ្តល់សក្ខីកម្មនៅក្នុងពេលជំនុំជម្រះ។ *សូមមើល* សេចក្តីជូនដំណឹងទៅភាគីពាក់ព័ន្ធនឹងនីតិវិធីនៃការកែសម្រួលការសួរសំណួរ និងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺទាក់ទងនឹងការប្រើប្រាស់ឯកសារនានាក្នុងពេលផ្តល់ផ្តល់សក្ខីកម្មរបស់សាក្សី (ឯកសារ E201) ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារលេខ E201/2 និងអនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "ការប្រគល់ចម្លើយមុនៗឱ្យសាក្សីមុនពេលសាក្សីធ្វើសក្ខីកម្មនៅសវនាការ" ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E141/1 (ដោយបានបញ្ជាក់ថា បែបបទអនុវត្តនេះ មានគោល

សារី និង ខៀវ សំផន បានសួរដេញដោលសាក្សី ទាក់ទិននឹងប្រធានបទមួយចំនួន ដូចជា បែបបទនៃការស្តាប់ចម្លើយរបស់ពួកគេនៅចំពោះមុខ ក.ស.ច.ស។ ក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្ម ផ្នែកមួយចំនួននៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយទាំងនេះ ក៏ត្រូវបានសួរឱ្យសាក្សីផ្តល់យោបល់ ឬបញ្ជាក់បំភ្លឺលើខ្លឹមសារ ឬសាកសួរអំពីភាពទុកចិត្តបាននៃសាក្សីទាំងនេះផងដែរ។ នៅដើមដំបូង អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ការស្តាប់សក្ខីកម្មរបស់សាក្សីទាំងនេះពុំមានអ្វីដែលបង្ហាញឱ្យឃើញកំហុសនៃការបំពេញកិច្ច ឬភាពមិនប្រក្រតីធ្ងន់ធ្ងរផ្សេងទៀតនៅក្នុងការស្តាប់ចម្លើយដែលបានធ្វើឡើងដោយអ្នកស៊ើបអង្កេត ក.ស.ច.ស ដូចជា ការគម្រាមកំហែង ការជម្រុញ ឬការបង្ហាញឱ្យឃើញជាក់ស្តែងនូវភាពលម្អៀងនៅក្នុងពេលធ្វើការស្តាប់ចម្លើយនោះឡើយ។

៣៣. អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ និងខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី ភី ភួន នាថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៧។ ខ្សែអាត់សម្លេងនេះស្តាប់ឮអ្នកស៊ើបអង្កេត និងសាក្សី អានកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ។ អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយនឹងក្រុមមេធាវីការពារក្តី អៀង សារី ថា ការសម្រេចរបស់ ក.ស.ច.ស ឱ្យអានកំណត់ហេតុសង្ខេបឱ្យសាក្សី ដើម្បីថតសម្លេងទុកនោះ ធ្វើឱ្យមានភាពមន្ទិល ហើយវាបានប៉ះពាល់គោលបំណងនៃការថតខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី។ ទោះបីជាយ៉ាងនេះក្តី ក្រុមមេធាវីការពារក្តី អៀង សារី មានកាតព្វកិច្ចចំបងត្រូវលើកឡើងបញ្ហានេះនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ដើម្បីស្នើសុំការកែតម្រូវមួយសមស្របក្នុងអំឡុងពេលពាក់ព័ន្ធនោះ។ អង្គជំនុំជម្រះពិចារណាឃើញថា ភាពមិនប្រក្រតីនេះពុំបានបំពេញលក្ខខណ្ឌអប្បបរមាក្នុងការបង្កើតជាភាពពុំស៊ីសង្វាក់គ្នាធ្ងន់ធ្ងរមួយរវាងចម្លើយសាក្សីដែលបានស្តាប់នាពេលមុនៗ និងសក្ខីកម្មរបស់សាក្សីរូបនេះនៅក្នុងពេលធ្វើសវនាការជំនុំជម្រះក្តីនោះទេ ហើយវាក៏ពុំប៉ះពាល់លើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីដែរ។ ទាំងសាក្សីរូបនេះ ទាំងភាគីនានា ត្រូវបានអនុញ្ញាតឱ្យផ្តល់យោបល់លើកាលៈទេសៈនៃការស្តាប់ចម្លើយនេះក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មសាក្សីរូបនេះក្នុងពេលសវនាការ[៧២]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ពុំចាំបាច់ត្រូវកោះហៅអ្នកបកប្រែដែលមានវត្តមានក្នុងអំឡុងពេលនៃការស្តាប់ចម្លើយសាក្សី ភី ភួន ដែលបានធ្វើឡើងជាមួយនឹង ក.ស.ច.ស នោះទេ។

៣៤. ក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្ម សាក្សី អឿន តាន បានបញ្ជាក់ថា លោកក៏ត្រូវបានអ្នកស៊ើបអង្កេត ក.ស.ច.ស ស្តាប់ចម្លើយនៅថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៨ ប្រហែលជាពេញមួយថ្ងៃផងដែរ ហើយលោក

បំណងជៀសវាងការខ្ជះខ្ជាយពេលវេលាដ៏មានតម្លៃក្នុងពេលសវនាការ និងដើម្បីផ្តល់ឱកាសឱ្យសាក្សីនឹកឃើញឡើងវិញនៅមុនពេលផ្តល់សក្ខីកម្ម)។

[៧២] ប្រតិចារឹក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៦១-៦៥ ទំព័រ ៦៩-៧២។ ប្រតិចារឹក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៨១។ ប្រតិចារឹក ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៣-១៦ ទំព័រ ៨៣-៨៦។

00867447

ក៏បានបញ្ជាក់ផងដែរថា លោកបានឆ្លើយសំនួរទាំងឡាយដែលបានចោទសួរមកលោកដោយអ្នកស៊ើបអង្កេត ប៉ុន្តែលោកបានបញ្ជាក់ថា ការស្តាប់ចម្លើយនោះពុំបានថតជាខ្សែអាត់សម្លេងឡើយ[៧៣]។ ខ្សែអាត់ថតសម្លេងនៃការស្តាប់ចម្លើយនាថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ក៏បានបញ្ជាក់ផងដែរថា សាក្សីត្រូវបានសួរសំនួរមុននេះមួយថ្ងៃ[៧៤]។ សាក្សី និងភាគីនានា បានផ្តល់យោបល់អំពីកាលៈទេសៈនៃការស្តាប់ចម្លើយនេះរួចហើយ។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញ ភាពមិនប្រក្រតីនានាដូចបានចោទប្រកាន់ដោយក្រុមមេធាវីការពារក្តីនៅត្រឹមបញ្ហានីតិវិធី ហើយខកខានពុំបានលើកឡើងការព្រួយបារម្ភដោយមានមូលដ្ឋានត្រឹមត្រូវពាក់ព័ន្ធនឹងភាពទុកចិត្តបាននៃដំណាក់កាលស៊ើបសួរ។ ក្រុមមេធាវីការពារក្តី អៀង សារី ក៏ខកខានពុំបានផ្តល់មូលដ្ឋានលើការចោទប្រកាន់របស់ខ្លួនដែលបានលើកឡើងថា កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយលើសាក្សី អៀន គាន នាថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ "គឺគ្រាន់ជាការលេងផ្តិនភ្នែក" និង "បំភាន់" អង្គជំនុំជម្រះតែប៉ុណ្ណោះ[៧៥]។ នៅក្នុងខ្សែអាត់សម្លេងថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ អ្នកស៊ើបអង្កេតខ្លួនឯងបានបញ្ជាក់ថា ខ្សែអាត់សម្លេងពុំបានថតទុកនៅថ្ងៃនោះមុនមួយថ្ងៃនោះទេ[៧៦]។ ការបញ្ជាក់ ទាំងនេះ ពុំមានភាពស៊ីសង្វាក់នឹងចេតនាណាមួយរបស់អ្នកស៊ើបអង្កេតចង់បំភាន់អង្គជំនុំជម្រះនោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងកាលៈទេសៈទាំងនេះខ្លួនពុំចាំបាច់ស្នើសុំការបញ្ជាក់បំភ្លឺបន្ថែមពី ក.ស.ច.ស លើបញ្ហានេះឡើយ ឬ ពុំចាំបាច់ផ្តល់មូលដ្ឋានចំពោះការចោទប្រកាន់ធ្ងន់ធ្ងរទាំងនេះដែលក្រុមការពារក្តី អៀង សារី បានចោទប្រកាន់ចំពោះសហចៅក្រមស៊ើបអង្កេតនោះទេ។

៣៥. ដូចគ្នានេះដែរ នៅក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មសាក្សី នង សុផង់ សាក្សីរូបនេះត្រូវបានចោទសួរ ហើយសាក្សីរូបនេះក៏បានបញ្ជាក់ថា ខ្លួនក៏ត្រូវបានអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ស្តាប់ចម្លើយនៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៩ ប្រហែលជាមួយម៉ោងផងដែរ ប៉ុន្តែការជួបនាពេលនោះពុំបានថតសម្លេងនោះទេ[៧៧]។ សាក្សីបានបញ្ជាក់ថា អ្នកស៊ើបអង្កេតបានប្រាប់គាត់និយាយតែការពិត ដោយឆ្លើយចម្លើយរបស់គាត់ក្នុងរង្វង់នៃបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់តែប៉ុណ្ណោះ[៧៨]។ ខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយនាថ្ងៃទី ១៨ ខែ

---

[៧៣] ប្រតិចារឹក ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ទំព័រ ២៥-៣៥ ទំព័រ ៤៥-៥១។

[៧៤] *ឧ.* ប្រតិចារឹកត្រង់ផ្នែកខ្លះនៃការស្តាប់ចម្លើយសាក្សី អៀន គាន ដែលមានការថតទុក ឯកសារលេខ D107/2.1 ទំព័រ ៤។

[៧៥] សំណើសុំលើកទីពីររបស់ អៀង សារី កថាខណ្ឌ ៦-៨។

[៧៦] ប្រតិចារឹកត្រង់ផ្នែកខ្លះនៃការស្តាប់ចម្លើយសាក្សី អៀន គាន ដែលមានការថតទុក ឯកសារលេខ D107/2.1 ទំព័រ ៤។

[៧៧] ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ ទំព័រ ៦០-៦៥ និងទំព័រ ៨៧-១០១។ ប្រតិចារឹក ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១២ ទំព័រ ២៩-៤៨។

[៧៨] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ ទំព័រ ១០១។

កុម្ភៈ ឆ្នាំ ២០០៩ ក៏លើកឡើងអំពីករណីដែលសាក្សីត្រូវបានសួរសំនួរនៅមុននោះមួយថ្ងៃផងដែរ[៧៩]។ ដូច្នេះ អង្គជំនុំជម្រះយល់ឃើញថា នៅក្នុងកាលៈទេសៈទាំងនេះ អង្គជំនុំជម្រះពុំចាំបាច់ស្នើសុំការបញ្ជាក់បំភ្លឺបន្ថែមពី ក.ស.ច.ស លើបញ្ហានេះ ឬ ក៏ត្រូវកោះហៅអ្នកស៊ើបអង្កេតនោះទេ។

### ៣.៣.៣. *សេចក្តីសន្និដ្ឋាន*

៣៦. អង្គជំនុំជម្រះជឿថា ក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងអស់ បានទទួលឱកាសគ្រប់គ្រាន់ក្នុងការតទល់ជាមួយនឹងសាក្សីខាងលើទាំងនេះរួចមកហើយ អំពីបញ្ហាចោទប្រកាន់នៃភាពពុំស៊ីសង្វាក់គ្នារវាងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ និងខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយធ្វើឡើង ជាមួយនឹង ក.ស.ច.ស ព្រមទាំងនៅក្នុងអំឡុងពេលធ្វើសវនាការស្តាប់សក្ខីកម្មផ្ទាល់មាត់ផងដែរ។ អង្គជំនុំជម្រះយល់ឃើញថា ភាពមិនប្រក្រតីទាំងនេះដូចបានចោទប្រកាន់ដោយក្រុមមេធាវីការពារក្តី ពុំបង្កើតជាភាពខុសគ្នាសំខាន់ ឬធ្ងន់ធ្ងរ ដែលទំនងជាប៉ះពាល់ជាអវិជ្ជមានលើភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីជំនុំ-ជម្រះនោះទេ។ ការចោទប្រកាន់លើចេតនាអាក្រក់របស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ពុំមានមូលដ្ឋានត្រឹមត្រូវបង្ហាញតាមរយៈសម្ភារៈឯកសារណាមួយដែលបង្កើតជាផ្នែកមួយនៃកំណត់ហេតុ ឬតាមរយៈចម្លើយតបនានារបស់សាក្សីទាំងនេះទៅនឹងសំនួររបស់ចៅក្រម ឬភាគីនានា ក្នុងពេលជំនុំជម្រះនោះឡើយ[៨០]។

---

[៧៩] ប្រតិចារឹកត្រង់ផ្នែកខ្លះនៃការស្តាប់ចម្លើយសាក្សី នង សុផង់ ដោយមានការថតទុក ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេត ឯកសារលេខ D200/3 ទំព័រ ២។

[៨០] ការចោទប្រកាន់ជាច្រើនដែលបានលើកឡើង មានលក្ខណៈជាន់គ្នា ហើយត្រូវបានសម្រេចនៅក្នុងសេចក្តីសម្រេចមួយចំនួនរបស់អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង (*សូមមើល ឧ.* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតសម្រេចបដិសេធសំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរទាំងអស់ (D263/1) ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារលេខ D263/2/6។ ដីកាសម្រេចបដិសេធសំណើសុំមោឃភាព និងសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធីធ្វើឡើងដោយ អៀង ធីរិទ្ធ ចុះថ្ងៃទី ៣១ ខែ ធ្នូ ២០០៩ ឯកសារលេខ D264/1។ សាលដីកាលើពាក្យបណ្តឹងជិតចិត្តរបស់ជនជាប់ចោទ អៀង សារី ចំពោះសហចៅក្រមស៊ើបអង្កេត ចៅក្រម Marcel LEMONDE ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៩ សំណុំរឿងលេខ ០០២/០៩-១០-២០០៩-អវតក/អបជ(០១) ឯកសារលេខ ៧)។

00867449

## ៣.៤ ការហាមឃាត់ការស៊ើបអង្កេតដោយភាគី

៣៧. អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចបើកការស៊ើបសួរថ្មីដោយខ្លួនឯងបាន នៅក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ[៨១]។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់រួចហើយថា អនុលោមតាមវិធាន ៥៥ នៃវិធានផ្ទៃក្នុង ភាគីពុំមានសិទ្ធិធ្វើការស៊ើបអង្កេតដោយខ្លួនឯងនោះទេ ទោះបីជាភាគីអាចធ្វើការសាកសួរបឋមណាដែលចាំបាច់បំផុតសម្រាប់ការអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តាមរយៈការដាក់សំណើសុំឱ្យបើកកិច្ចស៊ើបសួរក៏ដោយ[៨២]។ ក្រុមមេធាវីការពារក្ដី អៀង សារី បានដឹងច្បាស់អំពីការហាមឃាត់នេះ ហើយបានលើកឡើងជាច្រើនលើកច្រើនសារនៅក្នុងពាក្យសុំរបស់ខ្លួនកាលពីពេលមុនៗ[៨៣] ព្រមទាំងទទួលបានការព្រមានមួយពីសហចៅក្រមស៊ើបអង្កេត នៅក្នុងអំឡុងពេលនៃកិច្ចស៊ើបសួរផងដែរ[៨៤]។

៣៨. យោងតាមសំណើសុំទីមួយរបស់ អៀង សារី ក្រោយពីបានលើកបញ្ហានៃភាពខុសគ្នារវាងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ និងខ្សែអាត់សម្លេងនៃការស្ដាប់ចម្លើយសាក្សី ភី ភួន ក្នុងអំឡុងពេលធ្វើសវនាការថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១២ រួចមក និងក្រោយពីបានធ្វើសំណើសុំអង្គជំនុំជម្រះ

---

[៨១] ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កិច្ចស៊ើបសួរថ្មីមួយចាំបាច់ធ្វើឡើងនោះ អង្គជំនុំជម្រះសាលាដំបូងអាចចាត់តាំងចៅក្រមម្នាក់ឱ្យបំពេញកិច្ចស៊ើបសួរបាន។ ចៅក្រមរូបនេះត្រូវបំពេញកិច្ចតាមលក្ខខណ្ឌដូចគ្នានឹងសហចៅក្រមស៊ើបអង្កេត។ *សូមមើល* វិធាន ៩៣(១) និង (២) នៃវិធានផ្ទៃក្នុង។

[៨២] *សូមមើល ឧ.* អនុស្សរណៈ ក.ស.ច.ស ដែលមានចំណងជើងថា "សេចក្ដីចម្លងនៃចម្លើយរបស់យើងចំពោះលិខិតរបស់សហមេធាវីរបស់លោក នួន ជា ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០០៧ ទាក់ទិននឹងការដឹកនាំការស៊ើបអង្កេត" ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០៨ ឯកសារលេខ A110/II។ ករណីនេះត្រូវបានសម្រេចតម្កល់ដោយអង្គជំនុំជម្រះសាលាដំបូង។ សូមមើលអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សេចក្ដីជូនដំណឹងរបស់មេធាវីការពារជនជាប់ចោទ នួន ជា មកអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធទៅនឹងការស្រាវជ្រាវនៅឯមជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E211)" ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារលេខ E211/2 កថាខណ្ឌ ២ និងកថាខណ្ឌ ៥។

[៨៣] *ឧ.* សំណើសុំស៊ើបអង្កេតតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ដើម្បីកំណត់ថាតើការិយាល័យព្រះរាជអាជ្ញាបាន ឬ មិនបានស៊ើបអង្កេតលើសំណុំរឿង ០០២ ដោយគ្មានការអនុញ្ញាត ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១២ ឯកសារលេខ D374 កថាខណ្ឌ ៥។ *សូមមើលផងដែរ* ការឆ្លើយតបរបស់ អៀង សារី ចំពោះសំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំដាក់បញ្ចូលឯកសារភស្តុតាងទៅក្នុងសំណុំរឿង ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១០ ឯកសារលេខ D366/1 កថាខណ្ឌ ៥។ បណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០៨ ឯកសារលេខ A190/II/1 កថាខណ្ឌ ១៧។ *សូមមើលផងដែរ* សំណើសុំលើកទីបីរបស់លោក អៀង សារី កថាខណ្ឌ ២០។

[៨៤] ដីកាសម្រេចស្ដីពីការព្រមាន ដោយអនុវត្តតាមវិធាន ៣៨ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ D367 កថាខណ្ឌ ៦-៩ (ដែលបានបញ្ជាក់ថា ក្រុមមេធាវីការពារក្ដី អៀង សារី ត្រូវបានហាមឃាត់មិនឱ្យធ្វើការស៊ើបអង្កេតដោយខ្លួនឯង)។

ឱ្យស្តាប់ចម្លើយអ្នកបកប្រែដែលមានវត្តមានក្នុងអំឡុងពេលនៃការស្តាប់ចម្លើយធ្វើឡើងដោយ ក.ស.ច.ស រួចមកនោះ ក្រុមមេធាវីការពារក្តី អៀង សារី នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ បានទៅជួបនិយាយដោយផ្ទាល់ជាមួយនឹងអ្នកបកប្រែនោះ[៨៥]។ អង្គជំនុំជម្រះយល់ឃើញថា ទង្វើរបស់ក្រុមមេធាវីការពារក្តី បង្កើតបានជាការសម្ភាសន៍ជាមួយនឹងអ្នកដែលអាចក្លាយជាសាក្សីលើបញ្ហាមួយដែលកំពុងស្ថិតនៅក្រោមការពិចារណារបស់អង្គជំនុំជម្រះ ហើយវាហួសពីសិទ្ធិធ្វើការសាកសួរបឋមដែលត្រូវស្នើសុំតាមរយៈការបំពេញកិច្ចស៊ើបសួរ។ ហេតុដូច្នេះ ការធ្វើបែបនេះពុំត្រឹមត្រូវ និងបានបំពានលើវិធានផ្ទៃក្នុងផងដែរ[៨៦]។ លើសពីនេះ ការសម្ភាសន៍នេះត្រូវបានធ្វើឡើងដោយបុគ្គលទាំងឡាយ ដែលក្នុងនាមជាភាគីនៃកិច្ចដំណើរការនីតិវិធីពុំមានសិទ្ធិសច្ចធារណ៍នៃភាពមិនលម្អៀង ហើយត្រូវបានធ្វើឡើងដោយគ្មានការកត់ត្រាទុក។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះចេញការព្រមានមួយដោយអនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង ដល់ក្រុមមេធាវីការពារក្តីថា ក្រុមមេធាវីការពារក្តី ត្រូវបានហាមឃាត់មិនឱ្យបំពេញការស៊ើបសួរទាំងនេះឡើយ ហើយការបំពានណាមួយលើបទប្បញ្ញត្តិនេះ អាចនឹងនាំឱ្យមានការដាក់ទណ្ឌកម្ម។

## ៣.៥. ការពុំអនុញ្ញាតឱ្យលាតត្រដាងឯកសារមុនពេលធ្វើចំណាត់ថ្នាក់

៣៩. ចំណុចចុងក្រោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ចំណុចដកស្រង់ចេញពីសំណើសុំលើកទីបី និងលើកទីបួនរបស់ក្រុមមេធាវីការពារក្តី អៀង សារី ឃើញមានសរសេរនៅក្នុងអត្ថបទសារព័ត៌មានចេញផ្សាយថ្ងៃទី ២៤ ខែ កញ្ញា និងថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដោយអ្នកសារព័ត៌មានឈ្មោះ Julia Wallace និង Abby Seiff ក្នុងកាសែតក្នុងស្រុក *ឌឹខែមបូឌាដេលី* និង*ភ្នំពេញប៉ុស្តិ៍*[៨៧]។ អត្ថបទចេញផ្សាយទាំងនេះ បង្កើតជាការលាតត្រដាងដោយពុំមានការអនុញ្ញាតមួយលើឯកសារដែលរង់ចាំការធ្វើចំណាត់ថ្នាក់ដោយអង្គជំនុំជម្រះ។ ដោយកំពុងរង់ចាំការបកប្រែជាភាសាខ្មែរ និងដោយកំពុងរង់ចាំការដាក់ឯកសារចូលនៅក្នុងសំណុំរឿង ក្រុមមេធាវីការពារក្តី អៀង សារី បានថតចម្លងសំណើសុំមួយច្បាប់ដាក់ជូនអង្គជំនុំជម្រះ និងភាគីផ្សេងទៀតនៅថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១២ ដើម្បីជូនជាដំណឹង។ សំណើសុំលើកទីបីរបស់ក្រុមមេធាវីការពារក្តី អៀង សារី ពុំបានដាក់រហូតដល់ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១២ និងត្រូវបានធ្វើចំណាត់ថ្នាក់ថាជាឯកសារសាធារណៈ។ សំណើសុំលើកទីបួនរបស់ក្រុមមេធាវី ការពារក្តី អៀង

---

[៨៥] ប្រតិចារឹក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១២ ទំព័រ ៨៣-៨៦។ *សូមមើលផងដែរ* សំណើសុំលើកទីមួយរបស់ អៀង សារី កថាខណ្ឌ ៧។

[៨៦] *សូមមើលផងដែរ* វិធាន ៣៥(១)(ឃ) និងវិធាន ៣៥(៥) នៃវិធានផ្ទៃក្នុង (ពាក់ព័ន្ធនឹងការជ្រៀតជ្រែកសាក្សីសក្ខានុពល)។

[៨៧] ចម្លើយសាក្សីជាច្រើនទៀតត្រូវបានក្រុមមេធាវីការពារក្តី អៀង សារី សួរដេញដោល កាសែត ឃែមបូឌាដេលី ចេញផ្សាយថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១២ ទំព័រ ១៨។ សវនាការដេញដោលកំណត់ហេតុស្តាប់ចម្លើយ៖ ក្រុម អៀង សារី កាសែត ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៤។

សារី ត្រូវបានដាក់ជូននៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ហើយដំណើរការដាក់ឯកសារ រួមទាំងការជូនដំណឹងដល់ភាគី និងសាធារណជនផងនោះ បានធ្វើឡើងនៅថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១២។ ដើម្បីផលប្រយោជន៍នៃតម្លាភាព អង្គជំនុំជម្រះសាលាដំបូងបានធ្វើចំណាត់ថ្នាក់ឯកសារភាគច្រើន និងឯកសារផ្សេងទៀតដែលបានដាក់នោះ ជាឯកសារសាធារណៈ ប៉ុន្តែអង្គជំនុំជម្រះក៏មានឆន្ទានុសិទ្ធិក្នុងការសម្រេចអំពីវិធីធ្វើចំណាត់ថ្នាក់ឯកសារពាក់ព័ន្ធនៅក្នុងសំណុំរឿងដដែល[៨៨]។ ការសម្រេចនេះនឹងចប់សព្វគ្រប់ក្រោយពេលភាគីដាក់ឯកសារ និងក្រោយពេលអង្គជំនុំជម្រះធ្វើការជូនដំណឹង[៨៩]។ អង្គជំនុំជម្រះបានណែនាំដល់អ្នកតំណាងសារព័ត៌មានរួចហើយអំពីផលប៉ះពាល់ដែលអាចកើតមាននៃការលាតត្រដាងដោយគ្មានការអនុញ្ញាតនូវសម្ភារៈឯកសារទៅលើផលប្រយោជន៍របស់ជនរងគ្រោះ សាក្សី និងកិច្ចដំណើរការនីតិវិធីជំនុំជម្រះទាំងមូល។ ក្រោយពីពេលមានហេតុការណ៍នេះកើតឡើង អង្គជំនុំជម្រះ បានអញ្ជើញអ្នកតំណាងសារព័ត៌មានឱ្យទាក់ទងជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង (តាមរយៈផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក) ក្នុងករណីចាំបាច់ ដើម្បីឱ្យជួយផ្ទៀងផ្ទាត់ថាតើសម្ភារៈ ឯកសារដែលពួកគេមានក្នុងដៃទាំងនោះជាឯកសារសាធារណៈដោយស្របច្បាប់ដែរ ឬទេ[៩០]។

**ហេតុដូច្នេះហើយ អង្គជំនុំជម្រះសាលាដំបូង:**

**បដិសេធ** សំណើសុំលើកទីមួយ លើកទីពីរ លើកទីបី និងលើកទីបួនរបស់ក្រុមមេធាវីការពារក្តី អៀង សារី។

**បដិសេធ** សំណើសុំលើកទីមួយ លើកទីពីររបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន រួមទាំងសំណើសុំចូលរួមនៅក្នុងសំណើសុំលើកទីបួនរបស់ក្រុមមេធាវីការពារក្តី អៀង សារី។

**បដិសេធ** សំណើសុំចូលរួមរបស់ក្រុមមេធាវីការពារក្តី នួន ជា នៅក្នុងសំណើសុំលើកទីបីរបស់ក្រុមមេធាវីការពារក្តី អៀង សារី។

---

[៨៨] *សូមមើលផងដែរ* សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១២ ឯកសារលេខ E116/1/7 កថាខណ្ឌ៣៧។

[៨៩] ក្រោយពេលដែលឯកសារមួយច្បាប់បានដាក់រួចរាល់ហើយនោះ វាអាចមានការពន្យារពេល ដោយសារតែបញ្ហារដ្ឋបាល មុនពេលមានការសម្រេចលើការចាត់ចំណាត់ថ្នាក់លើឯកសារនេះ និងមុនពេលការជូនដំណឹងបានធ្វើឡើង។ ការពន្យារពេលបែបនេះជាពិសេស កើតឡើងនៅក្នុងករណីស្មុគស្មាញ ដែលពាក់ព័ន្ធនឹងចុងចោទច្រើននាក់ ការប្រើប្រាស់ភាសាការងារខុសៗគ្នា និងឯកសារច្រើនសន្ធឹកសន្ធាប់។

[៩០] *សូមមើល* សេចក្តីប្រកាសព័ត៌មានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើកំហុសវិជ្ជាជីវៈរបស់ក្រុមមេធាវីការពារក្តី នួន ជា" ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២។

**ព្រមាន** ក្រុមមេធាវីការពារក្ដី អៀង សារី អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង ដោយហាមឃាត់ក្រុមមេធាវីការពារក្ដី អៀង សារី មិនឱ្យបើកកិច្ចស៊ើបសួរនានា ហើយការបំពានណាមួយលើបទប្បញ្ញត្តិនេះ អាចនាំឱ្យមានការដាក់ទណ្ឌកម្មលើក្រុមមេធាវីការពារក្ដី។

**រម្លឹក** អ្នកតំណាងសារព័ត៌មានថា ពួកគេអាចទាក់ទងជាមួយនឹងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង តាមរយៈផ្នែក កិច្ចការសាធារណៈនៃ អ.វ.ត.ក ឱ្យជួយផ្ទៀងផ្ទាត់ថាតើសម្ភារៈឯកសារដែលពួកគេមាននោះជា ឯកសារដែលអាចផ្សព្វផ្សាយជាសាធារណៈបានដែរ ឬយ៉ាងណា។

ភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**